ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១៦៦/២៣ ក.ជ.ក

# របាយការណ៍ឆមាសទី១ ឆ្នាំ២០២៣
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆមាសទី២ ឆ្នាំ២០២៣

## I. ស្ថានភាពទូទៅ

សភាពការណ៍សាកលលោក មានការវិវត្តប្រែប្រួលថ្មីៗ ប្លែកៗ គួរឱ្យកត់សម្គាល់ និងមិនអាចប៉ាន់ស្មានបាន មានដូចជា គ្រោះធម្មជាតិ បម្រែបម្រួលអាកាសធាតុ (ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី អាកាសធាតុឡើងកំដៅ ភ្លើងឆេះព្រៃ...) ដែលបាន និងកំពុងគំរាមកំហែងដល់ការរស់នៅរបស់មនុស្សសត្វលើផែនដី បន្ថែមពីលើសង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន រួមទាំងមានគ្រោះមហន្តរាយដោយការរាតត្បាតនៃវីរុសកូវីដ-១៩ និងមេរោគបំប្លែងថ្មីៗ។ វិបត្តិនៃផលប៉ះពាល់ដោយជំងឺកូវីដ-១៩ មិនទាន់បានបញ្ចប់ផង ក៏មានព្រឹត្តិការណ៍ដ៏អាក្រក់ជាច្រើនដែលកើតឡើងជាបន្តបន្ទាប់នៅក្នុងឆ្នាំ២០២៣នេះ នោះគឺការផ្ទុះសង្គ្រាមរវាងប្រទេសដែលនៅជិតខាងគ្នានៅក្នុងទ្វីបអឺរ៉ុប គឺសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន បានជះឥទ្ធិពលអវិជ្ជមានធ្វើឱ្យមានវិបត្តិសេដ្ឋកិច្ច និងសង្គមជាសាកល ដែលជាកត្តាជំរុញឱ្យមានលំហូរទេសន្តរប្រវេសន៍។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរិត និងបណ្តាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយ បង្កើតនូវបទល្មើសថ្មីៗ ព្រមជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប សម្រាប់ទាក់ទាញជនរងគ្រោះ ឱ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស។

រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមដ៏ធំធេង និងខិតខំការពារសន្តិសុខក្នុងប្រទេស និងក្នុងតំបន់ ខិតខំរកដំណោះស្រាយបញ្ហាដោយទន់ភ្លន់បញ្ចៀសការប្រឈមមុខដាក់គ្នា និងការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហការក្នុងតំបន់ ដាក់ស្តែងជោគជ័យនៃការដោះស្រាយបញ្ហាតំបន់ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០២២នេះ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងដ៏ច្រើនសន្ធឹកសន្ធាប់ ក្នុងការដោះស្រាយភាពប្រឈមដែលជះឥទ្ធិពលជាអវិជ្ជមានដល់ជីវភាពប្រជាពលរដ្ឋ និងបង្កភាពរាំងស្ទះដល់ការអនុវត្តសកម្មភាពអភិវឌ្ឍគ្រប់វិស័យ រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសេនាធិការនៅគ្រប់កម្រិត បានរៀបចំយុទ្ធសាស្រ្ត និងដាក់ចេញនូវវិធានការចម្បងៗជាច្រើន រាប់ទាំងការកសាងច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តនានា ដើម្បីការពារប្រជាពលរដ្ឋពីភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចនានា។ ក្នុងស្ថានភាពដ៏អាក្រក់នៃភាពប្រឈមនឹងការស្វែងរកការងារនៅក្រៅប្រទេសដោយប្រថុយប្រថាន ក្នុងឋានៈជាពលករមិនស្របច្បាប់ រាជរដ្ឋាភិបាលកម្ពុជា តែងស្វះស្វែងរកដំណោះ

ស្រាយជាមួយប្រទេសពាក់ព័ន្ធដើម្បីកាត់បន្ថយភាពរងគ្រោះ និងលើកកម្ពស់សុវត្ថិភាពពលករចំណាកស្រុក ព្រមទាំងដោះស្រាយភាពប្រឈមរបស់ពលករវិលត្រឡប់រាប់សិបម៉ឺននាក់ និងប្រជាពលរដ្ឋក្នុងស្រុកដែលប្រឈមនឹងវិបត្តិកូវីដ-១៩ តាមរយៈការដាក់ចេញនូវគោលនយោបាយសន្តិសុខសង្គម យ៉ាងទូលំទូលាយ ដើម្បីបង្ការទប់ស្កាត់ភាពទ័លច្រក និងប្រថុយប្រថានរបស់ប្រជាពលរដ្ឋ ដែលជឿលើការអូសទាញរបស់មេខ្យល់ ឬឧក្រិដ្ឋជនឱ្យធ្លាក់ក្នុងភាពរងគ្រោះ។

ថ្មីៗនេះ មិនត្រឹមតែប្រជាជនកម្ពុជាទេ តែប្រជាជននៃប្រទេសដទៃក្នុងតំបន់ រហូតដល់ពីបណ្តាប្រទេសធំៗក្នុងពិភពលោក ក៏បានធ្លាក់ក្នុងភាពរងគ្រោះដោយកលល្បិចឧក្រិដ្ឋជន។ បញ្ហាជួញដូរមនុស្ស បានក្លាយជាវិបត្តិសាកលដែលស្ទើរតែគ្រប់ប្រទេសក្នុងសាកលលោកកំពុងប្រឈម ដោះស្រាយ និងកាន់តែស្មុគស្មាញខ្លាំងឡើង។

ប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស នាំឱ្យខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

ក្នុងឆមាសទី១ ឆ្នាំ២០២៣ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ជាសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងមានការចូលរួមគាំទ្រសហការដោយអង្គការដៃគូជាតិ និងអន្តរជាតិ ពាក់ព័ន្ធបានបន្តធ្វើសកម្មភាពប្រតិបត្តិការ តាមយុទ្ធសាស្ត្រដែលបានកំណត់។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌៖ បានរៀបចំបន្តពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស» និងច្បាប់ស្តីពី «អំពើពពោះជំនួស»។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖ បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ ស្តីពី«ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌៖

ក.សន្ធិសញ្ញាស្តីពី "ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ" បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី "ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ" ចំនួន៣គឺ៖

- រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋឥណ្ឌា។
- រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋបេឡារុស។
- រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋតួកគី។

ខ.សន្ធិសញ្ញាស្តីពីបត្យាប័ន៖ បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "បត្យាប័ន" រវាងព្រះរាជាណាចក្រកម្ពុជាជាមួយ សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។

គ.សន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត៖ បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "ការផ្ទេរទណ្ឌិត" រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនិងសាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្របែលហ្សិក។

### ៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់

- **ក្រសួងមហាផ្ទៃ៖** បានចុះអនុស្សរណៈនៃការយោគយល់ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និង អង្គភាពការពារកុមារ នៃអង្គការមូលនិធិកុមារកម្ពុជា CPU ស្តីពីការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និង យុត្តិធម៌ព្រហ្មទណ្ឌ សម្រាប់អនីតិជន នៅព្រះរាជាណាចក្រកម្ពុជា។
- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** បានរៀបចំកិច្ចប្រជុំពិភាក្សា៖ ១-កែសម្រួលអនុស្សរណៈ នៃការយោគយល់ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការងារទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ការសង្គ្រោះ ការស្តារឡើងវិញ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ២-លើសេចក្តីព្រាងអនុស្សារណៈនៃការយោគយល់(MOU) រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ពាក់ព័ន្ធនឹងកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន។

### ៤.លិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖បានដឹកនាំក្រុមការងារចូលរួមកិច្ចប្រជុំក្រុមបច្ចេកទេសចង្អៀត ដើម្បីពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជា។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។
- **ក្រសួងកិច្ចការនារី** បានរៀបចំសេចក្តីព្រាង៖
  - -វិសោធនកម្មអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ(COMMIT)។
  - -យន្តការបញ្ជូនឆ្លងដែនមានលក្ខណៈស្តង់ដាររួមគ្នាតែមួយ និងរួមទាំងចាត់តាំងគ្រូបង្គោល របស់ប្រទេសជាសមាជិកខមមីត(COMMIT)នីមួយៗ។
  - -អនុស្សរណៈនៃការយោគយល់ រវាងក្រសួងកិច្ចការនារី និងអង្គការសម្ព័ន្ធចាប់ដៃ ក្នុងគោលបំណងពង្រឹង៖ ១-ការប្រឹក្សាយោបល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ នៅតាមសហគមន៍។ ២-កិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូក្នុង និងក្រៅប្រទេស ក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ។ ៣-ការផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ជាពិសេសស្ត្រី និងកុមារ។
- **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍៖** កំពុងត្រៀមរៀបចំបង្កើតសេចក្តីណែនាំដល់ប្រតិបត្តិករទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឱ្យបន្តចូលរួមក្នុងសកម្មភាពទប់ស្កាត់ និងការពារកុមារលើប្រព័ន្ធអនឡាញ ព្រមទាំងទប់ស្កាត់ហានិភ័យការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។
- **បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា** សហការជាមួយ **អង្គការ IJM** បានតាក់តែង៖ ១-សៀវភៅលំហាត់អនុវត្តន៍នៃរឿងក្តីជួញដូរមនុស្ស សម្រាប់កម្មវិធីបណ្តុះបណ្តាលដល់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាទៅតាមនីតិវិធីក្នុងបទល្មើសជួញដូរមនុស្ស។ ហើយសៀវភៅនេះនឹងត្រូវប្រើប្រាស់ជាឯកសារឧទ្ទេស សម្រាប់កម្មវិធីបណ្តុះ-បណ្តាលទូទៅ និងជួយដល់គ្រូបង្គោលក្នុងការស្វែងយល់លំអិតលើចំណុចសំខាន់ៗ និងគោលបំណងទាំងមូល។ ២-និងបានបញ្ចប់កំណែសេចក្តីព្រាងនៃសៀវគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស សម្រាប់គ្រូបង្គោល។

## ៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ៥.១.កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** មានកិច្ចសហការក្នុងការពិភាក្សា៖ **ក**/-ដើម្បីពិនិត្យ និងពិភាក្សារបាយការណ៍សិក្សារៀបចំដោយវិទ្យាស្ថានអភិវឌ្ឍន៍បរទេស(ODI)តាមប្រព័ន្ធអនឡាញ។ **ខ**/-លើផែនការអនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដារ (SOP)៖ ភាគីទាំងពីរ កម្ពុជា-ថៃ ដោយបានឯកភាពបន្តពិភាក្សា លើការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដារ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេរភាគី ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស ហើយការពិភាក្សានេះផ្តែកចំនួនពីរ៖ (**១**)-ការរៀបចំផែនការអនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដារ ស្តីពីការតាមដានករណី ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដែលបានចុះហត្ថលេខា រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សថៃ ពីឆ្នាំ២០១៩។ (**២**)-ការរៀបចំផែនការអនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដារ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការអនុវត្តច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស ដែលបានចុះហត្ថលេខាដោយគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សថៃ។ **គ**/-លោក Alex Duke នាយកអង្គការ ASEAN-ACT ប្រចាំតំបន់ និងសហការី ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា និងរចនាសម្ព័ន្ធ ក៏ដូចជាសកម្មភាពការងារ របស់ គ.ជ.ប.ជ និងកិច្ចសហប្រតិបត្តិការនានាជាមួយបណ្តាអង្គការជាតិ អន្តរជាតិ និងបណ្តាប្រទេសជាមិត្តទាំងនៅក្នុងតំបន់ និងពិភពលោក។ **ឃ**/លោកឧត្តមសេនីយ៍ទោ **Siriwish Chantechasitkul** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃស្ថាប័ន ស៊ើបអង្កេតពិសេស (DSI) នៃរដ្ឋាភិបាលប្រទេសថៃ រួមនិងសាហការី ពាក់ព័ន្ធនឹងស្ថានភាពនៃអំពើជួញដូរមនុស្ស និងកិច្ចសហប្រតិបត្តិការ រវាងសមត្ថកិច្ចនៃប្រទេសទាំងពីរកម្ពុជា-ថៃ។

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖ បានដឹកនាំក្រុមការងារមានកិច្ចសហការទ្វេភាគីជាមួយ៖ **ក**/-ភាគីថៃ៖ (**១**)-ដើម្បីពិភាក្សាបន្តលើឧបសម្ព័ន្ធនៃផែនការសកម្មភាព នៃនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ (**២**)-ស្តីពី "នីតិវិធីប្រតិបត្តិស្តង់ដា ស្តីពីកិច្ចសហប្រតិបត្តិការ ការអនុវត្តច្បាប់រវាងកម្ពុជា និងថៃ"។ (**៣**)-ចូលរួមសិក្ខាសាលាលើកកម្ពស់ការអនុវត្តសារាចរ ស្តីពីការអនុវត្តអនុសាសន៍ របស់គណៈកម្មាធិការសិទ្ធកុមារនៃអង្គការសហប្រជាជាតិ (ស.អ.យ) និងការរៀបចំផែនការឆ្លើយតបទៅនឹងអនុសាសន៍។ **៤**-ស្តីពីការគ្រប់គ្រងពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។ **ខ**/-ជាមួយប្រតិភូប្រទេសឡាវ ដើម្បីចែករំលែកបទពិសោធន៍ក្នុងការទទួល និងដោះស្រាយវិវាទទាក់ទងនឹងពលករទេសន្តរប្រវេសន៍ ការទទួលនិងការធ្វើសមាហរណកម្មពលករ ដែលបានវិលត្រឡប់ ក្នុងអំឡុងពេលនិងក្រោយពេលការរីករាលដាលជំងឺកូវីដ-១៩។

- **ក្រសួងកិច្ចការនារី** ៖ បានសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) រៀបចំការអភិវឌ្ឍសូចនាករយេនឌ័រ ដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សក្រោមក្របខណ្ឌខមមីត" ក្នុងគោលបំណងប្រមូលធាតុចូលពីតំណាងក្រសួង ស្ថាប័នភាគីពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ក្នុងការរៀបចំសូចនាករយេនឌ័រ និងបង្ហាញពីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះដើម្បីរៀបចំកិច្ចប្រជុំថ្នាក់មហាអនុតំបន់មេគង្គប្រឆាំងអំពើជួញដូរមនុស្ស (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម)។

## ២. ការបង្ការ ទប់ស្កាត់

### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

### ១.១. ការផ្សព្វផ្សាយផ្ទាល់

សរុបការផ្សព្វផ្សាយដោយផ្ទាល់ក្នុងឆមាសទី១ ឆ្នាំ២០២៣ តាមរយៈយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងវេទិកាផ្សព្វផ្សាយជាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**" និងតាមកម្មវិធីផ្សេងៗ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ រាជធានី-ខេត្ត បានសហការជាមួយអង្គការដៃគូ សរុបចំនួន **១១៩.៣០៦លើក** មានអ្នកចូលរួមសរុបចំនួន **៤.០៥៤.៣៦៥**នាក់ (ស្ត្រីចំនួន **២.០៦០.៤៤៩**នាក់) (ធៀបនឹងឆមាសទី១ ឆ្នាំ២០២២ មានចំនួន **២.៣៤៣.០៣៧**នាក់) គឺមានការកើនឡើងចំនួន **១.៧១១.៣២៨**នាក់ ស្មើនឹង **៤២,២០%** ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការផ្សព្វផ្សាយផ្ទាល់**

| ការផ្សព្វផ្សាយផ្ទាល់ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| ទិវាជាតិអន្តរសាសនា | ០១ | ៣៣៧ | ៥០ |
| យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត | ០១ | ១.១៥០ | ៥៤៧ |
| ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងវេទិកាផ្សព្វផ្សាយសាធារណៈ | ១១៦.០២៦ | ៣.៧៨៥.៣៨៧ | ១.៩២៦.០១៦ |
| កម្មវិធីផ្សេងៗ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ | ៣.១៦១ | ២៤៣.០០៧ | ១២០.៧០៦ |
| អង្គការដៃគូ | ១១៧ | ២៤.៤៨៤ | ១៣.១៣០ |
| **សរុប** | **១១៩.៣០៦ លើក** | **៤.០៥៤.៣៦៥ នាក់** | **២.០៦០.៤៤៩ នាក់** |

#### ១.១.១.ការផ្សព្វផ្សាយតាមយុទ្ធនាការ

❖ **ទិវាជាតិអន្តរសាសនា**

▪ **គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តស្វាយរៀង** សហការជាមួយអង្គការដៃគូ បានរៀបចំវេទិកាផ្សព្វផ្សាយ អន្តរសាសនាស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រោមប្រធានបទ "រួមគ្នាបញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើគ្រប់រូបភាព "មានការអញ្ជើញចូលរួម ពីព្រះមន្ត្រីសង្ឃព្រះអនុគណ ព្រះគ្រូចៅអធិការវត្ត លោកគ្រូអាចារ្យវត្ត បូជាចារ្យ គ្រូគង្វាល ថ្នាក់ដឹកនាំនៃគ្រីស្តសាសនា សាសនាមហាយាន ឥស្លាម សាសនា និងសមាគមបាហៃសាសនា ឯកឧត្តម លោកជំទាវអភិបាលរងខេត្ត លោក លោកស្រីអភិបាលរងក្រុង ស្រុកទាំង០៣ មន្ទីរពាក់ព័ន្ធនៃក្រុមការងារទាំង ០៦ កងកម្លាំងទាំង ៣ប្រភេទ សរុបប្រមាណ **៣៣៧**អង្គ/នាក់ (ស្រី **៥០**នាក់)

❖ **យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ APLE បានរៀបចំកម្មវិធីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «តោះ! នាំគ្នានិយាយអំពីការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាពសម្រាប់កុមារ» ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ **តំណាងដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ដោយមានការអញ្ជើញចូលពីតំណាងក្រសួង ស្ថាប័ន អង្គភាពជាសមាជិកក្រុមការងារបង្ការ ទប់ស្កាត់ អភិបាលរង និងប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត អង្គការអភិវឌ្ឍន៍ដៃគូជាតិ និងអន្តរជាតិ ប្រតិបត្តិករទូរគមនាគមន៍ អ្នកផលិតមាតិកា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្ស សរុបប្រមាណ **១.១៥០**នាក់(ស្ត្រី **៥៤៧**នាក់) នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

### ១.១.២. ការផ្សព្វផ្សាយតាមរយៈភូមិសង្កាត់មានសុវត្ថិភាព-ឃុំ- និងវេទិកាសាធារណៈ

ឆមាសទី១ ឆ្នាំ២០២៣នេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈវេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**" ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **១១៦.០២៦**លើក មានអ្នកចូលរួមសរុបចំនួន **៣.៧៨៥.៣៨៧**នាក់ ស្ត្រីចំនួន **១.៩២៦.០១៦**នាក់ (ធៀបនឹងឆមាសទី១ ឆ្នាំ២០២២ មានចំនួន **២.៣១២.៧៧៣**នាក់ គឺមានការកើនឡើងចំនួន ចំនួន **១.៤៧២.៦១៤**នាក់ ស្មើនឹង **៣៨,៩០១%**) ដូចមានតារាងលម្អិតខាងក្រោម៖

តារាងទិន្នន័យផ្សព្វផ្សាយតាមរយៈភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ភូមិ-ឃុំមានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | ក្រសួងការ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣១ | ១.៧៧៨ | ៨៥៦ | | | |
| ២ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ | ០២ | ១៥០ | ៦០ | | | |
| ៣ | ក្រសួងកិច្ចការនារី | ០១ | ១១៩ | ៧៩ | | | |
| ៤ | កាកបាទក្រហមកម្ពុជា | ០៣ | ២.១៦៦ | ២៨៧ | | | |
| ៥ | សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ថ្នាក់កណ្តាល | ៧៤ | ៦.៨០២ | ៧៤៦ | | | |
| ៦ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៧៨៣ | ៧៨.៦៤៤ | ៤១.៧៥៣ | ៤.២០៧ | ១២៤.៨២១ | ៧០.៩១៨ |
| **សរុប ក្រសួង ស្ថាប័ន** | | **៨៩៤** | **៨៩.៦៥៩** | **៤៣.៧៨១** | **៤.២០៧** | **១២៤.៨២១** | **៧០.៩១៨** |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ១០ | ៥០២ | ៤១៥ | ០១ | ១២០ | ៥៧ |
| ២ | ខេត្តកណ្តាល | ៤.៨៦៥ | ២៤៥.៦៨៥ | ១២៣.៣២៥ | ៨.៤០៣ | ៦០១.៨៩២ | ៣០២.៤៦៨ |
| ៣ | ខេត្តបាត់ដំបង | ៤១.០១៧ | ២៦៣.០៩៤ | ១៣៨.៨២១ | ៣.៨៤០ | ១៣៩.៥០៥ | ៧៣.២៤៩ |
| ៤ | ខេត្តពោធិ៍សាត់ | ២.៨៦២ | ២៨៦.៩៤៥ | ១៤៧.៦០២ | ១.១១៤ | ៣១.២២៦ | ១៥.៤៣៨ |
| ៥ | ខេត្តសៀមរាប | ៧៧៣ | ៨៥.២៩៩ | ៥២.៨៨២ | ៣៦៣ | ១៣.១៣៤ | ៩.៨១៦ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៤.៩៩៣ | ១២៨.០៨៦ | ៥៦.៧៧៦ | ២.៥៦៨ | ៦១.៩៦៩ | ៣២.២១៨ |
| ៧ | ខេត្តកំពង់ចាម | ១១.១៨៨ | ៥៦០.៤០១ | ២៨៧.៨៤៨ | ០៥ | ៣២៣ | ១៤៤ |
| ៨ | ខេត្តព្រះសីហនុ | ២១៥ | ១៥.៤៨៤ | ៨.២២៩ | ៣៦ | ៥.២៤៨ | ២.៩៦៥ |
| ៩ | ខេត្តព្រះវិហារ | ១០៣ | ៣០.២៩៤ | ១៨.២៦១ | ២១ | ២៦០ | ១១១ |
| ១០ | ខេត្តស្វាយរៀង | ៣៥០ | ១១.៥០៣ | ៦.៨០១ | ៣.១៥៦ | ១០៥.០១៣ | ៥៥.៥៤០ |
| ១១ | ខេត្តប៉ៃលិន | ៤៤២ | ៥៩.៦០៧ | ១.៧៥០ | ២០៣ | ៧.៧៩២ | ២.៣៥២ |
| ១២ | ខេត្តកោះកុង | ០៤ | ១២២ | ៩៣ | ៥៦៩ | ១០.៩៧៧ | ៥.៣៤៤ |
| ១៣ | ខេត្តកំពត | ៦៨ | ៣.០៧៦ | ១.៨៧៦ | ៥៣ | ១.៦៥១ | ៨៦២ |
| ១៤ | ខេត្តកំពង់ធំ | ២.២៥០ | ៣២២.៣៦៤ | ១៨០.១៩៥ | ១១៦ | ៧.៨៣១ | ៤.១៦០ |
| ១៥ | ខេត្តតាកែវ | ២.២៦៥ | ៧០.៦៨៥ | ៣៧.៥៦១ | ៦១១ | ២១.៥៦៥ | ១១.១៤៨ |
| ១៦ | ខេត្តក្រចេះ | ៧៨ | ៦.៧៨៦ | ៣.៦៨៣ | ៣១ | ១.១៨៨ | ៨១២ |
| ១៧ | ខេត្តកែប | ១៨៣ | ៣៣.០០១ | ១៨.៥០២ | ៣៤០ | ១៥.៣១៤ | ១២.២៣០ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៤៤០ | ៧៥.៤៤០ | ៣៣.៦៤៤ | ១៦ | ៣.៦០៦ | ៨៣២ |
| ១៩ | ខេត្តស្ទឹងត្រែង | ១២ | ៨៦៤ | ៦១៩ | ០០ | ០០ | ០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២០ | ខេត្តរតនគិរី | ៣៤ | ៦៧៨ | ២៤៦ | ៧៨៨ | ២៧.៩០០ | ១.១៥៥ |
| ២១ | ខេត្តព្រៃវែង | ៩១០ | ២៣.៧៤៤ | ១២.៤៦៥ | ៧១ | ៣.៩៦០ | ២.៤១៣ |
| ២២ | ខេត្តត្បូងឃ្មុំ | ១២.៧៨៨ | ១៣៧.២០៣ | ៧២.៣៥២ | ២.៣៥៣ | ៣៣.៨៩០ | ១៤.៤៦០ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១៦៩ | ១០៩.៥០០ | ៥៥.៦២០ | ១០ | ២.៥០៤ | ១.៣៤៧ |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣៧ | ២.០១៦ | ១.៣៨១ | ០២ | ៧២ | ៥១ |
| ២៥ | ខេត្តមណ្ឌលគិរី | ១៩៩ | ២.៤០៦ | ១.១៩៨ | | | |
| សរុប រាជធានី-ខេត្ត | | ៨៦.២៥៥ | ២.៤៧៣.៩៦៧ | ១.២៦២.១៤៥ | ២៤.៦៧០ | ១.០៩៦.៩៤០ | ៥៤៩.១៧២ |
| សរុបរួម<br>ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន<br>១១៦.០២៦ លើក | | ចំនួនមនុស្ស<br>៣.៧៨៥.៣៨៧ នាក់ | | ចំនួនស្ត្រី<br>១.៩២៦.០១៦ នាក់ | |

### ១.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធធ្វើការផ្សព្វផ្សាយ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការប្រារព្ធពិធី និងរៀបចំ៖ **១**-ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធាន គ.ជ.ប.ជ**។ **២**-បញ្ជ្រាប គុណធម៌ សីលធម៌ដោយផ្សារភ្ជាប់ព្រះពុទ្ធសាសនាទៅក្នុងសង្គម។ **៣**-បញ្ជ្រាបផ្សព្វផ្សាយតាមការចាក់បញ្ចាំងភាពយន្ត និងសិល្បៈ ស្តីពីច្បាប់ទប់ស្កាត់អំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។ **៤**-ចុះតាមដាននិងផ្សព្វផ្សាយ ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន **៥**-ការចុះចែកស្បៀងដល់ពលករដែលទើបវិលត្រឡប់ពីប្រទេសថៃ។ **៦**-រៀបចំអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣។ **៧**-ចុះតាមដាន និងត្រួតពិនិត្យ និងផ្សព្វផ្សាយនៅតាមហាងខារ៉ាអូខេ និងហាងមាស្សា។ **៨**-កម្មវិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា។ **៩**-ការរៀបចំបើកបវេសនកាលឆ្នាំសិក្សាថ្មី។ **១០**-ការចុះត្រួតពិនិត្យ និងចុះសួរសុខទុក្ខ  នៅតាមគ្រឹះស្ថានសិក្សា វិទ្យាល័យ អនុវិទ្យាល័យ  រោងចក្រ សហគ្រាស និងនៅមណ្ឌលទទួលពលករ។ **១១**-ចុះផ្សព្វផ្សាយស្តីពីការកំណត់បែបបទ  និងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ  ជាមួយជនបរទេស។ **១២**-រៀបចំពិធីបើកយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ  នៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ  និងកសិឧស្សាហកម្ម។ ចំនួន **៣.២៧៨**លើក អ្នកចូលរួមចំនួន **២៦៧.៤៩១**នាក់ ក្នុងនោះស្ត្រី **១៣៣.៨៣៦**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| **សកម្មភាពការផ្សព្វផ្សាយ ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ** | **ចំនួនលើក** | **ចំនួនអ្នកចូល រួម** | **ចំនួនស្ត្រី** |
|---|---|---|---|
| អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ | ០១ | ៣៦០ | ១៩៨ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១០ | ១.២២១ | ៦០៤ |
| ក្រសួងធម្មការ និងសាសនា | ២៥ | ៨២១ | ៥២២ |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ០៤ | ២៥.១៣៧ | ១២.៤៣៦ |
| ខេត្តបន្ទាយមានជ័យ | ៤៥ | ២.០៥៧ | ១.១០១ |
| ខេត្តបាត់ដំបង | ១០ | ៤១៤ | ១៣៣ |
| ខេត្តពោធិ៍សាត់ | ២៩ | ៥.៦៧៩ | ២.៨១២ |
| ខេត្តសៀមរាប | ៨០ | ១.៦៤០ | ៩៩៦ |
| ខេត្តឧត្តរមានជ័យ | ០២ | ៣០៤ | ១៤៥ |

| | | | |
|---|---|---|---|
| ខេត្តកំពង់ធំ | ០១ | ១៩ | ០៩ |
| ខេត្តក្រចេះ | ០៧ | ៤.០៧៨ | ១.៣៥៣ |
| ខេត្តកំពង់ចាម | ២.៦១៦ | ១០៦.៩២៦ | ៥៦.៤៦៣ |
| ខេត្តកណ្តាល | ១៥ | ១.១៣៩ | ៣២៧ |
| ខេត្តព្រៃវែង | ១៥ | ៩.៣៦៩ | ៣.១១៨ |
| ខេត្តព្រះសីហនុ | ៥១ | ២.៤៣២ | ១.៤០៤ |
| ខេត្តតាកែវ | ០៦ | ១.១៩៤ | ១១៣ |
| ខេត្តរតនគិរី | ០៧ | ៧៧៦ | ២៦១ |
| ខេត្តកំពង់ឆ្នាំង | ២០ | ២១.២៩៣ | ១០.២២៧ |
| ខេត្តកំពង់ស្ពឺ | ២១៧ | ៥៨.១៤៨ | ២៨.៤៨៤ |
| សរុប | **៣.១៦១លើក** | **២៤៣.០០៧នាក់** | **១២០.៧០៦នាក់** |
| អង្គភាពការពារកុមារ CPU (រាជធានីភ្នំពេញ) | ០៣ | ៣១៣ | ១៤០ |
| អង្គការតំណក់ទឹក(ខេត្តបន្ទាយមានជ័យ) | ០៤ | ២៥៦ | ២១៤ |
| អង្គការកល្យាណមិត្ត(ខេត្តបន្ទាយមានជ័យ) | ០៦ | ៩៣១ | ៦៩១ |
| អង្គការអន្តរជាតិទេសន្តរប្រវេស៍(IOM)(ខេត្តបន្ទាយមានជ័យ | ០៥ | ២.៦៤៦ | ៨៩៣ |
| អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ) | ០១ | ៧៥ | ៤០ |
| អង្គការ UNICEFF(ខេត្តរតនគិរី) | ០៥ | ៨.៤៥៤ | ៥.០៩៨ |
| អង្គការមូលនិធិអេ២១ | ៤២ | ៦.៣៤៨ | ៣.២៣៣ |
| អង្គការអន្តរជាតិ(ILO)(ខេត្តបាត់ដំបង) | ០២ | ១៣៧ | ៦៧ |
| អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប) | ២២ | ២.៩៤៥ | ១.៤៣៦ |
| អង្គការជំហ៊ានដំបូងកម្ពុជា (ខេត្តសៀមរាប) | ០៦ | ១៥៦ | ៨៤ |
| អង្គការសកម្មភាពដើម្បីកុមារ (APLE) (ខេត្តសៀមរាប) | ១៥ | ១.៧២៧ | ១.០០៧ |
| អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) (ខេត្តកំពង់ចាម) | ០១ | ៦០ | ០០ |
| អង្គការ ILO (ខេត្តកំពង់ចាម) | ០១ | ១១៤ | ៤១ |
| អង្គការសម្ព័ន្ធចាប់ដៃ (ខេត្តកំពង់ចាម) | ០២ | ២១៤ | ១៣២ |
| អង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍(ខេត្តកំពង់ចាម) | ០១ | ៥៩ | ២៩ |
| អង្គការហ្វ្រីធូសាយ | ០១ | ៤៩ | ២៥ |
| **សរុប** | **១១៧លើក** | **២៤.៤៨៤នាក់** | **១៣.១៣០នាក់** |
| **សរុបរួម** | **៣.២៧៨លើក** | **២៦៧.៤៩១នាក់** | **១៣៣.៨៣៦នាក់** |

### ១.២. ការផ្សព្វផ្សាយមិនផ្ទាល់

១.២.១ ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ(វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក)

• **ក្រសួងព័ត៌មាន៖** មន្ទីព័ត៌មានខេត្តកំពង់ចាម បានផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអ៊ីនធឺណេត ភាពគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដោយខុសច្បាប់តាមរយៈវិទ្យុជាតភ្នំប្រុស ភ្នំស្រី FM ៩២-៥០MHz និងទូរទស្សជាតិខេត្ត ផេករបស់មន្ទីព័ត៌មាន AKP ខេត្ត។

•**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈគេហទំព័រហ្វេសប៊ុក មានអ្នកចូលមើលចំនួន **១៥.៧៦៥**នាក់។

•**ខេត្តសៀមរាប៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិ FM នគរភ្នំ ១០៣ MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្ដីពីកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារក្នុងស្រុកជាជាងការចំណាកដោយប្រថុយប្រថាន ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ចំនួន **៤៧៦**លើក (ផ្សាយផ្ទាល់ **២២០**លើក ចាក់ផ្សាយឡើងវិញ ចំនួន **២៥៦**លើក)។

•**ខេត្តព្រៃវែង៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយសារអប់រំតាមវិទ្យុបាវាយណ៍អណ្តែត ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **៣០០**លើក ក្នុងមួយថ្ងៃ **០៥**លើក។

•**ខេត្តកំពង់ឆ្នាំង៖ មន្ទីរអប់រំ យុវជន និងកីឡា** បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សតាមរយៈការប្រជុំតាមប្រព័ន្ធ Telegram ឬ Google Meet ទៅដល់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុកទាំង៨ ដើម្បីធ្វើការផ្សព្វផ្សាយបន្តទៅដល់ នាយក នាយិកា សិស្សានុសិស្ស នៅពេលគោរពទង់ជាតិមុនចូលរៀន និងក្នុងម៉ោងសិក្សាចំពោះមេរៀនដែលពាក់ព័ន្ធ ចំនួន **១៨**លើក។

•**ខេត្តត្បូងឃ្មុំ៖** បានធ្វើការផ្សព្វផ្សាយតាមវិទ្យុជាតិត្បូងឃ្មុំ FM ៨៨ MHz ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាពបានចំនួន **១.០៨០**លើក។

•**ខេត្តព្រះសីហនុ៖**ក្រុមលេខាធិការដ្ឋាន ដែលមានមន្ទីរកិច្ចការនារី សហការជាមួយក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង/ស្រុក ក្នុងខេត្តព្រះសីហនុ បានចុះផ្សព្វផ្សាយស្តីពី សុវត្ថិភាពកុមារនៅលើប្រព័ន្ធអនឡាញ ក្រោមប្រធានបទ“ស្វែងយល់ពីការប្រើប្រាស់អ៊ិនធើណែតរបស់កុមារកម្ពុជា” ក្នុងគោលបំណងទប់ស្កាត់ការជួញដូរមនុស្ស ការជួញដូរផ្លូវភេទ តាមប្រព័ន្ធអនឡាញ(ប្រព័ន្ធអ៊ិនធើណែត) ចំនួន **០២**លើក អ្នកចូលរួមសរុប **១០៦**នាក់ (ស្រី **៧៩**នាក់)។

•**អង្គការសាម៉ារីតាន់ភឺស៖**(ខេត្តបាត់ដំបង) បានសហការណជាមួយក្រុមយុវជន ធ្វើយុទ្ធនាការសម្តែងរឿងអប់រំខ្លីរបស់ យុវជន និងយុវនារីដល់យុវជន និងអាណាព្យាបាលរបស់យុវជន និងសហគមន៍ស្តីពី ការចំណាកស្រុកដោយសុវត្ថិភាព ទប់ស្កាត់ការជួញដូរមនុស្ស បានចំនួន ២ភូមិ គឺភូមិស្រឡៅជ្រុំ ឃុំសិរីមានជ័យ និងភូមិចំបក់ ឃុំជ្រៃសីម៉ា អ្នកចូលរួមសរុប ៣៩០នាក់ (ស្រី **១៧៤**នាក់)។

•**អង្គការមូលនិធិអេ២១** បានសហការណជាមួយអង្គការ IJM បានធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងតាមរយៈកម្មវិធីវិទ្យុ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន **០១**លើក អ្នកចូលរួមទស្សនា ចំនួន **២២០**នាក់។

**១.២.២ ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)**

•**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានផ្សព្វផ្សាយ និងចែកខិត្តបណ្ណព័ត៌មាន ស្ដីពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពដល់ពលករទេសន្តរប្រវេសន៍ និងប្រជាពលរដ្ឋដែលមានបំណងធ្វើទេសន្តរប្រវេសន៍ការងារ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច តាមរយៈមណ្ឌលធនធានពលករ (MRC) ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តកំពត និងខេត្តពោធិ៍សាត់។

•**ក្រសួងកិច្ចការនារី៖** បានចែករូបភាពសន្លឹកផ្ទាត់ ស្តីពី“ការលើកកម្ពស់សុវត្ថិភាពសម្រាប់ពលករចំណាកស្រុកជាស្ត្រី តាំងពីមុនចេញដំណើរ” ក្នុងគោលបំណងបណ្តុះបណ្តាលបន្តទៅមន្ត្រីថ្នាក់ខេត្ត/ស្រុក ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋបានយល់ដឹងពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសេវាគាំទ្រផ្សេងៗ បានចំនួន **០៣**ឈុត ដល់មន្ត្រីកិច្ចការនារីខេត្តប៉ៃលិន កំពង់ធំ និងខេត្តមណ្ឌលគិរី។

•**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ៖** នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ បានបញ្ចូលសារអប់រំពាក់ព័ន្ធការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សទៅក្នុង CD, VCD, DVD របស់ផលិតកម្មភាពយន្ត និងក្រុមហ៊ុននាំចេញ-នាំចូលខ្សែភាពយន្តបានចំនួន **១០៣**ផលិតកម្ម មាន **២៣**ក្រុមហ៊ុន និងសារចំនួន **១០០**សារ ស្មើនឹង **១០០**ទិដ្ឋាការ។

•**កាកបាទក្រហមកម្ពុជា៖** បានចែកខិត្តប័ណ្ណ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន **១.៦៩២**សន្លឹក ដល់ប្រជាពលរដ្ឋនៅតាមបណ្តារាជធានី-ខេត្ត។

•**ខេត្តសៀមរាប៖ ១-រដ្ឋបាលស្រុកពួក** បានធ្វើការផ្សព្វផ្សាយ និងចែកខិតប័ណ្ណស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព បានចំនួន ៤.៨៩១សន្លឹក មានអ្នកទទួល ប័ណ្ណចំនួន ២.២១៨នាក់(ស្រី ១.១៨៧នាក់)។ **២-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចែកខិតប័ណ្ណ សម្រាប់ផ្តល់ព័ត៌មានអំពីលេខទូរស័ព្ទក្នុងការទំនាក់ទំនង ដែលអាចរាយការណ៍សុំកិច្ចអន្តរាគមន៍ ក្នុងករណីបានឃើញ មានអំពើហិង្សា អំពើជួញដូរមនុស្ស និងការរំលោភបំពានលើស្ត្រីពលករចំណាកស្រុក ដល់ប្រជាពលរដ្ឋ ចំនួន **១៧២**សន្លឹក ដែលមានអ្នកទទួល ប័ណ្ណចំនួន **៥៧០**នាក់(ស្រី **២៦៦**នាក់)។ **៣-រដ្ឋបាលស្រុកអង្គរធំ** បានធ្វើការផ្សព្វផ្សាយ និងចែកខិតប័ណ្ណ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព បានចំនួន **១.៩៩៥**សន្លឹក។

•**ខេត្តបន្ទាយមានជ័យ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអង្គភាពពាក់ព័ន្ធ អាជ្ញាធរ ក្រុង ស្រុក បានសហការជាមួយអង្គការដៃគូ បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយច្បាប់ និងតាមរយៈចងបដា ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដូចជា៖

**១-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចងបដាដែលមានខ្លឹមសារ៖ ក**/-ហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម និងការប្រើប្រាស់ពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ គឺអាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ។ និងធ្វើការដាក់ទោស បើមានជនណាដែលនាំក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្មនឹងទទួលខុសត្រូវចំពោះមុខច្បាប់។ ខ/-ហាមឃាត់ដាច់ខាតរាល់ទម្រង់នៃការកេងប្រវ័ញ្ចពលកម្មលើកុមារ និងការបង្ខំឱ្យកុមារធ្វើការដើម្បីដោះបំណុល។

**២-អង្គការសាម៉ារីតាន់ភឺស** (Samaritan Purse) ចំនួនចំនួន **៩.៦៤២**សន្លឹក មានចំនួនមនុស្ស**២២.៦២១**នាក់ (ស្រី ៣.៣៤០នាក់) កុមារា **៥១៤**នាក់ កុមារី **៦១៦**នាក់។

៣-អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានអប់រំផ្សព្វផ្សាយ និងចែកខិត្តប័ណ្ណសរុបចំនួន **៥.៥៣០**សន្លឹក មានអ្នកទទួលចំនួន ៥.៥៣០នាក់ (ស្ត្រី **២.១៣៤**នាក់) កុមារ **៣៥៦**នាក់(កុមារី **១៧៥**នាក់)។

**៤-អង្គការតំណក់ទឹក** បានចុះធ្វើបណ្ណាល័យចល័ត ដើម្បីអប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពីចំណាក ស្រុកប្រកបដោយសុវត្ថិភាព អ្នកចូលរួម ៨៥នាក់ ស្រី៣៨នាក់។

**៥-អង្គការ UNFPA** ចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងចែកកញ្ចប់ឃីតចំនួន ៨៤ឃីតដល់ពលករ។

•**ខេត្តកំពង់ស្ពឺ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានបិទផ្ទាំងបដាផ្សព្វផ្សាយ ស្តីពីអំពើការប្រយុទ្ធប្រឆាំងជួញដូរមនុស្សក្នុងកម្មវិធីទិវាជាតិ ១២ធ្នូ ចំនួន **១០**កន្លែង ស្មើនឹង **១៥**ផ្ទាំង។

•**អង្គការសម្ព័ន្ធចាប់ដៃ៖** បានចែកផ្ទាំងរូបភាព និងខិតប័ណ្ណស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន **២១**រូបភាព និងខិតប័ណ្ណចំនួន **៨០០**សន្លឹក ដល់សិក្ខាកាម ដែលចូលរួមវគ្គសិក្ខាសាលាក្នុងខេត្តកំពង់ចាម និងក្នុងវគ្គបណ្តុះបណ្តាលនៅខេត្តត្បូងឃ្មុំ បានចែករូបភាពចំនួន **១៤**ឈុត និងខិតប័ណ្ណចំនួន **១.៤៩៨**សន្លឹក ។

•**អង្គការអេ២១** (ខេត្តសៀមរាប) បានចែករំលែកសម្ភារទាក់ទង និងកម្មវិធីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់អាជ្ញាធរមូលដ្ឋាននិងសហគមន៍ បានចំនួន **៤៣៥**ខិតប័ណ្ណ មានចំនួនមនុស្សចូលរួម **៤៣៥**នាក់។

•**អង្គការជំហានដំបូងកម្ពុជា** (គម្រោងកិច្ចការពារជំនាន់ថ្មី) តាមរយៈរៀបចំសិក្ខាសាលាផ្សព្វផ្សាយ បានបង្កើតរឿងខ្លីបានចំនួន**០២**លើក និងផ្សព្វផ្សាយតាមផ្ទាំងរូបភាពបានចំនួន **០៤** ស្តីពីរបៀបការពារខ្លួនពីការរំលោភបំពានផ្លូវភេទ អ្នកចូលរួមសរុប **១៣២**នាក់ (ស្រី **៧៣**នាក់)។

**១.២.៣ ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

•**គណៈកម្មាធិការជាតិ គ.ជ.ប.ជ ៖** លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងកម្មវិធីកិច្ចពិគ្រោះយោបល់លើកទី២ ជាមួយសង្គមស៊ីវិល ស្តីពីការតាមដានលើសេចក្តីសង្កេតសន្និដ្ឋាន របស់គណៈកម្មាធិការសិទ្ធិមនុស្ស លើរបាយការណ៍តាមកាលកំណត់លើកទី៣ រៀបចំដោយ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។

•**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចូលរួមជាវាគ្មិនៈ **១**-ក្នុងកម្មវិធីវិទ្យុលើប្រធានបទ "ការស្វែងរកការងារធ្វើក្រោយវិបត្តិកូវីដ-១៩" នៅស្ថានីយវិទ្យុស្ត្រី FM ១០៣.៥ , **២**-ធ្វើបទបង្ហាញស្តីពី "ការស្នើសុំកូតាប្រើប្រាស់ហត្ថពលកម្មបរទេស និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករបរទេសរបស់ប្រទេសកម្ពុជា" នៅ Singapore (Cambodia) International Academy , **៣**-ក្នុងកម្មវិធីវិទ្យុវាយោ FM ១០៥.៥ MHZ ក្រោមប្រធានបទ "ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យការងារ" ។ **៤**-ក្នុងសិក្ខាសាលាថ្នាក់ជាតិ សម្រាប់ប្រមូលធាតុចូលក្នុងការបង្កើត "ប្រព័ន្ធគ្រប់គ្រងករណីសេវាសង្គម"។

•**អគ្គលេខាធិការ គ.ជ.ប.ជ៖ ១**-ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ FM 103.5 ដែលមានប្រធានបទវេទិកាស្ត្រីប្រចាំខែ ស្តីពីការទប់ស្កាត់អំពើជួញដូមនុស្ស ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីផលប៉ះពាល នៃអំពើជួញដូរមនុស្ស និងលទ្ធផលការបង្ក្រាបអំពើជួញដូរមនុស្សឆ្នាំ២០២២ និងទិសដៅឆ្នាំ២០២៣, **២**-ប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ បានចូលរួមជាវាគ្មិនក្នុងកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និង ក្រុមការងារខេមមីតកម្ពុជា ដោយបានធ្វើបទបង្ហាញសង្ខេប ស្តីពីស្ថានភាពបច្ចុប្បន្ននៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា, **៣**-ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍បានចូលរួមជាវាគ្មិនដើម្បីចែករំលែកព័ត៌មាន គន្លឹះសំខាន់ៗជាចំណេះដឹង និងឆ្លើយតបនូវរាល់ចម្ងល់របស់អ្នកស្តាប់ ក្នុងកម្មវិធីសន្ទនាមតិ «ជីវិតយើង សង្គមយើង» នៅស្ថានីយ៍វិទ្យុជាតិកម្ពុជា AM918KHz និងវិទ្យុវត្តភ្នំ FM 105.70 MHz ដែលពិភាក្សានូវប្រធានស្តីពី«សុវត្ថិភាពការធ្វើចំណាកស្រុកក្នុងស្រុករបស់កូនស្រី»។

•**ខេត្តកំពង់ចាម៖ (ក)**-តំណាងស្នងការរដ្ឋាននគរបាល បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ ចំនួន **០៥**លើក ក្រោមប្រធានបទ ស្តីពី៖ **១**-ទប់ស្កាត់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមា តាមប្រព័ន្ធអ៊ីនធឺណែត, **២**-ភាពគ្រោះថ្នាក់ក្នុងការធ្វើចំណាកស្រុកដោយខុសច្បាប់ **៣**-ការទប់ស្កាត់ភាពមិនប្រក្រតីក្នុងទិវាបុណ្យនៃក្តីស្រលាញ់, **(ខ)**-តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិនកម្មវិធីសន្ទនាមតិ ក្រោមប្រធានបទស្តីពី៖ **១**-ការផ្សព្វផ្សាយច្បាប់ និងការចំណាកស្រុកដោយសុវត្ថិភាព, **២**-ទប់ស្កាត់ពលករចំណាកស្រុកទៅក្រៅប្រទេសដែលគ្មានឯកសារស្របច្បាប់។ **៣**-លើកកម្ពស់ជីវភាពស្ត្រីនិងកុមារក្រីក្រតាមរយៈការបង្កើតមុខរបរផ្សេងៗ។ **(គ)**-តំណាងមន្ទីរកិច្ចការនារី បានចូលរួមជាវាគ្មិន ក្រោមប្រធានបទ រួមគ្នាលុបបំបាត់ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ គ្រប់រូបភាព។

•**ខេត្តបាត់ដំបង៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមធ្វើជាវាគ្មិនៈ **១**-នៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន **០៣**លើក មានអ្នកចូលរួមចំនួន **១១៦** (ស្រី **៦៨**នាក់), **២**-ក្នុងកម្មវិធីសន្ទនាមតិ ក្រោមប្រធានបទ "ទប់ស្កាត់ការចំណាកស្រុកស្វែងរកការងារដោយខុសច្បាប់" និងស្តីពីការអន្តាគមន៍សម្រួលដល់ពលករចំណាកស្រុកដែលចង់វិលមក

ចូលរួមពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ នៅវិទ្យុជាតិចំការចក FM92.70 mhz , ៣-អំពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើការជួញដូរមនុស្ស និងការសម្ភាសបែបកោសល្យវិច័យ មានអ្នកចូលរួមចំនួន **៥៦** (ស្រី **៣០**នាក់)។

•**ខេត្តព្រះវិហារ៖** តំណាងស្នងការដ្ឋាននគរបាល បានចូលរួមជាវាគ្មិនក្នុងកម្មវិធីតាមបណ្តាញប្រព័ន្ធ សង្គមហ្វេសប៊ុក ក្រោមប្រធានបទ ស្តីពីការទប់ស្កាត់អំពើកេងប្រវ័ញ្ចផ្លូវភេទ ដែលរៀបចំឡើងដោយអង្គការអាដ្រា។

**២. ការបង្ការទប់ស្កាត់តាមវិធានការជំនាញ**

២.១. វិធានការបង្ការ ទប់ស្កាត់ ដោយការគ្រប់គ្រងចំណាកស្រុកខុសច្បាប់

•**អគ្គស្នងការដ្ឋាននគរបាលជាតិ៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលចំនួន **០៤**ខេត្ត បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងវៀតណាមចំនួន **២១**លើក មនុស្សចំនួន **៥១៤**នាក់ (ស្រី **២១៨**នាក់) អនីតិជន **២៧**នាក់ និងបានធ្វើកិច្ចសន្យាការអប់រំណែនាំ កុំឱ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យ ចំនួន **១៥**លើក មនុស្សចំនួន **២២៩**នាក់(ស្រី **៩៦**នាក់) អនីតិជន **១៨**នាក់។
- ខេត្តកោះកុង ចំនួន **០៣**លើក មនុស្សចំនួន **២០**នាក់ (ស្រី **០៨**នាក់)អនីតិជន **០៩**នាក់។
- ខេត្តកែប ចំនួន **០១**លើក មនុស្សចំនួន **២៦២**នាក់ (ស្រី **១១៤**នាក់)។
- ខេត្តត្បូងឃ្មុំ កម្លាំងនគរបាលជំនាញ បានសហការជាមួយភាគីវៀតណាមកម្លាំងប៉ុស្តិ៍ទិនហា (៨២១) និងធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរ **០១**នាក់ ដែលលួចឆ្លងដែនទៅវៀតណាម និងពលរដ្ឋវៀតណាម **០២**នាក់ ចូលមកប្រទេសកម្ពុជា សរុបចំនួន **០២**លើក។

•**ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ** បានធ្វើការសហការ និងសម្របសម្រួលជាមួយអាជ្ញាធរថៃ ដែលពលរដ្ឋខ្មែរឆ្លងដែនធ្វើការនៅប្រទេសថៃចំនួន **១៣០**នាក់(ស្រី **៧១**នាក់) ឱ្យបានចូលប្រទេសកម្ពុជាវិញ ដើម្បីបោះត្រាបើកប័ណ្ណព្រំដែនចេញទៅធ្វើការនៅប្រទេសថៃ។

២.២. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

▪ **ថ្នាក់ជាតិ៖**

•**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានត្រួតពិនិត្យ និងវាយតម្លៃលើប្រភេទការងារ និងលក្ខខណ្ឌការងារកម្មករនិយោជិតវ័យក្មេងចំនួន ៤ក្រុមហ៊ុន មានកម្មករនិយោជិតវ័យក្មេងសរុបចំនួន **០៨**នាក់ (ស្រី **០៤**នាក់)។

•**ក្រសួងអប់រំ យុវជន និងកីឡា** បានត្រួតពិនិត្យ និងតាមដាននូវការប្រើប្រាស់សៀវភៅបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស នៅវិទ្យាល័យចំនួន ០៣ មាន៖ វិទ្យាល័យ ១០មករា ១៩៧៩ វិទ្យាល័យរុនតាឯក និងវិទ្យាល័យអង្គរធំ ខេត្តសៀមរាប។

២.៣. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

២.៣.១. ការគ្រប់គ្រងស្ថិតិពលករខ្មែរ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

•**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** យោងតាមតាមរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០២៣នេះ ពលករខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈប្រព័ន្ធអនុគ្រោះមុខរបរ Employment Permit System(EPS) របស់រាជរដ្ឋាភិបាល មានចំនួនសរុប **២៥.៧៣៤**នាក់(ស្រី **១០.៨០៥**នាក់) ក្នុងនោះមាន៖

| | | |
|---|---|---|
| - ប្រទេសថៃ | ចំនួន **១៧.១២៦**នាក់ | (ស្រី **៧.៤៣៤**នាក់) |
| - សាធារណរដ្ឋកូរ៉េ | ចំនួន **៤.៥៥៥**នាក់ | (ស្រី **១.៥៨៦**នាក់) |
| - ប្រទេសជប៉ុន | ចំនួន **៤.០៣០**នាក់ | (ស្រី **១.៧៦២**នាក់) |
| - ប្រទេសសិង្ហបុរី | ចំនួន **២០**នាក់ | (ស្រី **២០**នាក់) |
| - តំបន់រដ្ឋបាលពិសេសហុងកុង | ចំនួន **០៣**នាក់ | (ស្រី **០៣**នាក់)។ |

➤ **និងបាន៖** ១-ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន និងប្រព័ន្ធតាមដាន ជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ រហូតដល់ពលករ វិលត្រឡប់មកមាតុប្រទេសវិញ។ ២-បានរៀបចំ និងពង្រឹងប្រព័ន្ធ OCWC (Oversea Cambodian Working Card) ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ ដូចជាការបែងចែកទៅតាមភេទ អាយុ កម្រិតអប់រំ និងប្រភេទការងាររបស់ពលករជាដើម សម្រាប់ធ្វើជាធាតុចូល ក្នុងការរៀបចំគោលនយោបាយ ឬបទដ្ឋានគតិយុត្ត។ ៣-បានពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីតាមដានលំហូរនីតិវិធីនៃការធ្វើទេសន្តរប្រវេសន៍ការងារនៅគ្រប់ប្រទេសទទួល។

• **អគ្គស្នងការដ្ឋាននគរបាលជាតិ៖**

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន **២២៩.១៣៦**នាក់ (ស្រី **១០១.៤២៧**នាក់) អនីតិជន **៣.៦២៧**នាក់(ស្រី **១.២៩៣**នាក់) ក្នុងនោះមាន៖

- ស្របច្បាប់ ចំនួន **១៧០.៦៨៦**នាក់ (ស្រី**៧៨.០៧៥**នាក់) អនីតិជន **២៨៥**នាក់(ស្រី **៩២**នាក់)
- មិនស្របច្បាប់ចំនួន **៥៧.៧៧៨**នាក់ (ស្រី**២៣.០៥៦**នាក់) អនីតិជន **៣.២៣៦**នាក់ (ស្រី **១.១៧១**នាក់)។
- ដាច់ការទាក់ទងចំនួន **៦៧២**នាក់ (ស្រី **២៩៦**នាក់) អនីតិជន **១០៦**នាក់(ស្រី **៣០នាក់**)។

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯងពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១២៥.២៥៣**នាក់ (ស្រី**៥៨.៤៥៤**នាក់) អនីតិជន **៤៩២**នាក់ (ស្រី **១៨០**នាក់)។

២.៣.២. ការគ្រប់គ្រងស្ថិតិជនបរទេស បច្ចុប្បន្នភាពចំណូលស្រុក

• **អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖**

**១-ការគ្រប់គ្រងស្ថិតិជនបរទេសចូលមកកម្ពុជាស្របច្បាប់ ៖**

**ក-គ្រប់គ្រងជនបរទេសអន្តោប្រវេសន៍៖**

១-ក្រោយបញ្ចប់យុទ្ធនាការជំរឿនស្ថិតិ និងដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី អគ្គនាយកដ្ឋានបានបង្កើនការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ ដោយបានរៀបចំបែបបទស្នើសុំក្រសួងមហាផ្ទៃ ផ្តល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ជូនអ្នកដែលមានអាយុ ១៨ឆ្នាំឡើង សរុបចំនួន **៦៧.៦២០**ប័ណ្ណ និងផ្តល់សុពលភាពរយៈពេល ០២ឆ្នាំម្តង ចំនួន **៥៤.៣០២**ប័ណ្ណ ក្នុងនោះបន្តលើកទី១ ចំនួន **៤២.២១៣**នាក់, លើកទី២ ចំនួន **១០.៣៨៥**នាក់, លើកទី៣ ចំនួន **១.៦៧៨**នាក់ និងលើកទី៤ ចំនួន **២៦**នាក់។ តាមការស្រាវជ្រាវទិន្នន័យនៃការផ្តល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ពិនិត្យឃើញថា មានជនអន្តោប្រវេសន្តចំនួន **១.៤៩០**នាក់ ដែលមិនទាន់មកដាក់ពាក្យស្នើសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ដែលបញ្ហានេះអគ្គនាយកដ្ឋានកំពុងមានវិធានការ ដើម្បីជំរុញឱ្យពួកគេគោរពតាមគោលការណ៍ច្បាប់ជាធរមាន។

២-ក្រៅពីនេះក៏បានយកចិត្តទុកដាក់ធ្វើការរៀបចំសំណុំឯកសារជនបរទេសអន្តោប្រវេសន៍ ដើម្បីរក្សាទុកយូរអង្វែងក្នុងប្រព័ន្ធ IMS មាន៖

-ស្កេនពាក្យសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ លើកទី១បានចំនួន **៥.១៣៧**នាក់ (ស្រី **៣.៥៤១**នាក់) លើ **២៣**រាជធានី ខេត្ត។

-ស្កេនពាក្យសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ លើកទី២បានចំនួន **៧.៧៧៣**នាក់ (ស្រី **២.៧៦៥**នាក់) លើ **២៣**រាជធានី ខេត្ត។

-ស្កេនពាក្យសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ លើកទី៣បានចំនួន **២០៥**នាក់(ស្រី **១៧១**នាក់) លើ ០២ខេត្ត។

**ខ-គ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជ និងហត្ថពលករបរទេស៖**

តាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា (CDC) គិតត្រឹមខែមីនា ឆ្នាំ២០២៣ ក្រុមហ៊ុនវិនិយោគបរទេសដែលបានចុះបញ្ជី មានចំនួនសរុប **៣.០៧៦**ក្រុមហ៊ុន **៨៤**សញ្ជាតិ ប្រៀបធៀបនឹងឆ្នាំ២០២២ កើនឡើងចំនួន **៣០**ក្រុមហ៊ុន ស្មើនឹង **២,៨០%** (ក្នុងនោះវិស័យកសិកម្ម ចំនួន **២៥៨**ក្រុមហ៊ុន មាន**១៩**សញ្ជាតិ វិស័យទេសចរណ៍ ចំនួន **១២៦**ក្រុមហ៊ុន មាន**១៧**សញ្ជាតិ, វិស័យហេដ្ឋារចនាសម្ព័ន្ធ **១៦១**ក្រុមហ៊ុន មាន **១៧**សញ្ជាតិ និងវិស័យរោងចក្រសហគ្រាស ចំនួន **២.៥៣១**ក្រុមហ៊ុន មាន **៤០**សញ្ជាតិ) មានទុនវិនិយោគសរុបចំនួន **៤៤.៧៦២.១១២.១៩៤**ដុល្លា និងផ្តល់ការងារដល់ពលករបរទេស-ខ្មែរ សរុប **៣.១១៦.២៧៣**កន្លែង។ ប្រទេសដែលមកដាក់ទុន វិនិយោគច្រើនជាងគេមានដូចជា៖ ប្រទេសចិន ចំនួន **១.៨៨៧**ក្រុមហ៊ុន, កូរ៉េខាងត្បូង **២២៣**ក្រុមហ៊ុន, សឹង្ហបូរី **១៤៧**ក្រុមហ៊ុន និងម៉ាឡេស៊ី **១៣៥**ក្រុមហ៊ុន។

ដោយឡែកការងារអធិការកិច្ចហត្ថពលកម្មបរទេស ក្រុមការងារអធិការកិច្ចពលកម្មបរទេស នៅតាមបណ្តាក្រុមហ៊ុន រោងចក្រសហគ្រាសនានា ក្រុមការងារទើបដំណើរការចុះនៅដើមខែឧសភានេះ បានចំនួន **៣៦៦**គោលដៅ មានពលករបរទេសចំនួន **៣.១៥៥**នាក់ រកឃើញពុំមានប័ណ្ណការងារចំនួន **២២**នាក់ ផាកបាន **១១.០០០.០០០**រៀល។

➢ **កត់សម្គាល់៖** គិតត្រឹមចុងខែឧសភា ឆ្នាំ២០២៣នេះ ពលករបរទេសមកធ្វើប័ណ្ណការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួន **២៥៥.៤០៣**នាក់ ប្រៀបធៀបរយៈពេលដូចគ្នានឹងឆ្នាំ២០២២ មានការកើនឡើងចំនួន **៥១.២៩១**នាក់ ស្មើនឹង **១៩២,៩៩%**។

**គ-ជនបរទេសមិនមែនអន្តោប្រវេសន៍ និងបច្ចេកវិទ្យា៖** ដើម្បីធានាការគ្រប់គ្រងវត្តមានជនបរទេស បម្រើឱ្យសំណូមពររក្សាសន្តិសុខ សុវត្ថិភាពសង្គម ក្នុងឆ្នាំនេះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់តាំងអនុវត្តសេចក្តីណែនាំលេខ ០២៨ ស.ណ.ន របស់ក្រសួងមហាផ្ទៃ ស្តីពីការរាយការណ៍វត្តមានស្នាក់នៅរបស់ជនបរទេសតាមមូលដ្ឋាន ដោយមានវិធានការក្នុងគោលដៅជំរុញការគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន្ត ឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការពិនិត្យស្នើឱ្យបំពេញអាសយដ្ឋានច្បាស់លាស់នៅក្នុងសាលកបត្រពេលមកដល់ ការពង្រឹងសំណុំឯកសារ បែបបទពេលមកស្នើសុំបន្តទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន និងរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដោយទទួលបានលទ្ធផលជាវិជ្ជមាន ដូចជាបាន៖ ១-ផ្តល់ទិដ្ឋាការចូលប្រទេសនៅតាមច្រកទ្វារអន្តរជាតិចំនួន **៦១៤.៨៥៦**នាក់ លើ **៦៤.៥៥៧**នាក់ កើន **៨៥២,៤២%**, ២-ផ្តល់ទិដ្ឋាការចេញចំនួន **២.២៩០**នាក់ លើ **៤៩៣**នាក់ កើន **៣៦៤,៥០%**, ៣-ផ្តល់ទិដ្ឋាការពិសេស ប្រភេទ K ចំនួន **២២.០៥៤**នាក់ ជូនពលរដ្ឋខ្មែរដែលរស់នៅប្រទេសក្រៅ, ៤-ផ្តល់ទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នចំនួន **២៩៨.៧៩៩**នាក់ លើ**១៩៩.៤៧០**នាក់ កើន **៤៩,៨០%**។

❖ ដោយឡែក ចំពោះអ្នកស្នាក់នៅហួសរយៈពេលកំណត់ក្នុងត្រីមាសទី១ ឆ្នាំ២០២៣នេះ មានចំនួន **១.៤២៥**នាក់ មាន **៦១**សញ្ជាតិ បានធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន**២៦២.៨៥០**ដុល្លារ បង់ចូលថវិកាជាតិ។

-អគ្គនាយកដ្ឋាន បានម្ចាស់ការកសាងដោយជោគជ័យ នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបម្រើឱ្យការងារគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហៅកាត់ថា (FPCS) និងបានដាក់ឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។ ជាលទ្ធផលក្នុងឆ្នាំ២០២៣នេះ ជនបរទេសបានរាយការណ៍ពីវត្តមានស្នាក់នៅព្រះរាជណាចក្រកម្ពុជានៅក្នុងប្រព័ន្ធ សរុបចំនួន **២០៨.៧០០**នាក់/ស្រី **៥៣.២១៧**នាក់។ (**កត់សម្គាល់៖** ចាប់ពីថ្ងៃដាក់អោយដំណើរការមកដល់បច្ចុប្បន្ន ប្រព័ន្ធនេះចុះវត្តមានជនបរទេសបានចំនួន **៦៦៨៣៦៥**.នាក់)។ ទន្ទឹមនោះបានភ្ជាប់គណនីជូនមន្ត្រីនគរបាលមានសមត្ថកិច្ចពាក់ព័ន្ធ ចំនួន **៤.២៣៤គណនី** ពិសេសប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ដើម្បីបម្រើឱ្យការងារគ្រប់គ្រងជនបរទេសនៅក្នុងមូលដ្ឋានរបស់ខ្លួន។

-បានបន្តយកចិត្តទុកដាក់ពង្រឹងការងារគ្រប់គ្រងបញ្ជីខ្មៅអន្តោប្រវេសន៍ ដើម្បីបម្រើឱ្យការងារបង្ការ ទប់ស្កាត់ការជ្រៀតចូលរបស់មុខសញ្ញាល្មើសច្បាប់មកក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសមុខសញ្ញាពាក់ព័ន្ធអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន ក៏ដូចជាការស្រាវជ្រាវកមុខសញ្ញានានាតាមសំណូមពរចាំបាច់របស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយបាន៖ **១**-បញ្ចូលទិន្នន័យមុខសញ្ញាថ្មីបន្ថែមចំនួន **១.៩២០**នាក់ មាន **៦២**សញ្ជាតិ(បូកយោងពីដើមគ្រាចំនួន **៣២.១១៥**នាក់) ក្នុងនោះប្រភេទមុខសញ្ញា (A, B, C, D, E) ចំនួន **២.៨៧០**នាក់ , **២**-ធ្វើការស្រាវជ្រាវប្រវត្តិអ្នកដំណើរតាមសំណើក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន **២.៧៦៦**នាក់ (**៧០**សញ្ជាតិ) ពី **១៧**ស្ថាប័ន ដោយបានរកឃើញ និងឆ្លើយតបចំនួន **២.៣៧១**នាក់។

**២-ការគ្រប់គ្រងស្ថិតិជនបរទេសចូលមកកម្ពុជាដោយមិនស្របច្បាប់៖** មន្ត្រីនគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិ រកឃើញអ្នកដំណើរមិនប្រក្រតី បទល្មើសសរុបចំនួន **៨១៩**លើក ជនល្មើសចំនួន **១.១០៥**នាក់ ក្នុងនោះ៖

- រកឃើញការលួចឆ្លងដែនដោយខុសច្បាប់ **៤៣**លើក ជនល្មើស **៩៩**នាក់ មាន **១០**សញ្ជាតិ
- រកឃើញការស្នាក់នៅ និងធ្វើការខុសច្បាប់ **១៦៣**លើក ជនល្មើស **៦២១**នាក់ មាន **១៧**សញ្ជាតិ
- រកឃើញការស្នាក់នៅលើសទិដ្ឋាការកំណត់ **១.៤២៥**លើក ជនល្មើស **១.៤២៥**នាក់ មាន **៦១**សញ្ជាតិ

**៣-ការបណ្តេញជនបរទេស ដែលចូលមកកម្ពុជាខុសច្បាប់**

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖** អគ្គនាយកដ្ឋាន បានឃាត់ខ្លួនជនបរទេស និងរៀបចំតាមនីតិវិធីបណ្តេញចេញជនបរទេសល្មើសច្បាប់ ចំនួនមនុស្ស **១.០៣៨**នាក់ មាន **២៩**សញ្ជាតិ (ច្រើនជាងគេ គឺជនជាតិចិន **៥៤៩**នាក់, ឥណ្ឌូនេស៊ី **១៦២**នាក់, ថៃ **២៦**នាក់ ,វៀតណាម **១២៩**នាក់, នីហ្សេរីយ៉ា **២៦**នាក់, ម៉ាឡេស៊ី **២៥**នាក់ ,ជប៉ុន **២០**នាក់ តៃវ៉ាន់ **១៧**នាក់, ឥណ្ឌា **១៧**នាក់, ហ្វីលីពីន **១៣**នាក់, កូរ៉េខាងត្បូង **១៣**នាក់ ,អាមេរិក **១០**នាក់ និង **១៧**សញ្ជាតិទៀត មានពី **០១** ដល់ **០៦**នាក់)។ គិតចាប់ពីបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ឆ្នាំ២០១៤ មកដល់ថ្ងៃទី៣១ខែមិថុនា ឆ្នាំ២០២៣នេះ បានបណ្តេញចេញជនបរទេសខុសច្បាប់ចំនួន **២៦.៦៨៩**នាក់ មានចំនួន **១០៧**សញ្ជាតិ។

២.៤.វិធានការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ** ៖ ស្នងការដ្ឋាននគរបាល និងកងរាជអាវុធហត្ថរាជធានី-ខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន **១៥៣**លើក និងធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់ជាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សាខារ៉ាអូខេ ជាប្រចាំ បានចំនួន **៧៦៩**គោលដៅ មានចំនួនមនុស្សសរុប ៤.**៥៦៣**នាក់(ស្រី **៣.០០២**នាក់)។

**២.៥.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

**ក្រសួងមហាផ្ទៃ៖** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន **៧៧២**នាក់ ក្នុងនោះ(ស្ត្រីខ្មែរ **៦៩០**នាក់ និងស្ត្រីបរទេស ៨៣នាក់) មាន**២៩**សញ្ជាតិ និងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន ៣៤នាក់(ស្រី ២៨នាក់)។

**៣. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្ម**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖ **(១)**-ចូលរួមពិនិត្យ និងផ្តល់ការឯកភាពក្នុងកិច្ចប្រជុំរបស់គណៈកម្មការការពារកុមារថ្នាក់ជាតិ ស្តីពីការត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៅខេត្តសៀមរាប, **(២)**-អនុវត្តកិច្ចអន្តរាគមន៍ស្តួលដកហូត ទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម ចំនួន **៣២០**ករណី ក្នុងខេត្តគោលដៅចំនួន៤ គឺខេត្តសៀមរាប ត្បូងឃ្មុំ កណ្តាល និងខេត្តកំពង់ចាម និងបានបន្តនិរន្តរភាពកុមារ ក្នុងគម្រោងដកហូតទប់ស្កាត់ពលកម្មកុមារចំនួន **១៥០**នាក់ (ស្រី **៧៩**នាក់)។

•**ក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** បានផ្សព្វផ្សាយការទប់ស្កាត់ពលកម្មកុមារនៅក្នុងវិស័យផលិតកម្ម និងអាជីវកម្មនានា ដល់មន្ត្រីក្រោមឱវាទ ដើម្បីបានផ្សព្វផ្សាយបន្តទូទាំងរាជធានី-ខេត្ត ដែលមានអ្នកចូលរួមចំនួន **៥០**នាក់(ស្រី **១២**នាក់)។

•**ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន៖ **១**-សហការជាមួយ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ បានបញ្ជ្រាបការផ្សព្វផ្សាយការលុបបំបាត់ពលកម្មកុមារ ក្នុងវិស័យផលិតឥដ្ឋតាមរយៈកម្មវិធីចែកកង់ និងសម្ភារសិក្សាដល់កុមារ មានអ្នកចូលរួមចំនួន **២២៨**នាក់ (ស្រី **៦៤**នាក់) ក្នុងនោះមានកុមារក្នុងមុខរបរផលិតកម្មដំឡូងមីចំនួន **៣១**នាក់ (ស្រី **១៤**នាក់) នៅស្រុករតនមណ្ឌល និងមុខរបរសិប្បកម្មផលិតឥដ្ឋចំនួន **៤៥**នាក់ (ស្រី **១៥**នាក់)។ **២**-ចុះធ្វើបច្ចុប្បន្នភាពទិន្នន័យសិប្បកម្មផលិតឥដ្ឋបានចំនួន **១៤**សិប្បកម្មផលិតឥដ្ឋដែលក្នុងនោះ ស្រុកមោងឫស្សីចំនួន **០៤** កន្លែង ស្រុកថ្មគោលចំនួន **០៤** កន្លែង ស្រុកសង្កែចំនួន **០២**កន្លែង និងក្រុងបាត់ដំបងចំនួន **០៤**កន្លែង ដែលមានកម្មករនិយោជិត **៣២៥**នាក់ (ស្រី **១៥៩**នាក់) ហើយមានកុមារស្នាក់នៅក្នុងសិប្បកម្មផលិតឥដ្ឋ **៦១**នាក់ (ស្រី **៣០**នាក់) តែពុំមានរកឃើញការកេងប្រវ័ញ្ចពលកម្មកុមារទេ។

•**ខេត្តសៀមរាប៖ ១-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះផ្សព្វផ្សាយតាមដានត្រួតពិនិត្យ និងទប់ស្កាត់ពលកម្មកុមារងាយរងគ្រោះ តាមស្រុកគោលដៅ ក្នុងវិស័យឧស្សាហកម្ម (ចំការដំឡូងមី និងសិប្បកម្មផលិតឥដ្ឋ) បានចំនួន **០២**លើក នៅតាមកសិឧស្សាហកម្មចំការដំឡូងមី និងចំការស្វាយចន្ទី ចំនួន **០៥**កន្លែង ដែលមានកម្មករសរុប **៧៨**នាក់ (ស្រី **៣៤**នាក់) នៅសិប្បកម្មផលិតឥដ្ឋ ចំនួន **៣០**កន្លែង មានកម្មករសរុប **១.០៩៥**នាក់ (ស្រី **៤៩៥**នាក់) ក្នុងនោះបានធ្វើការទប់ស្កាត់កុមារសរុប **៩០**នាក់ (ស្រី **៤២**នាក់) ដោយបានជួយឧបត្ថម្ភសម្ភារសិក្សា សម្លៀកបំពាក់ និងកង់ ដើម្បីឱ្យកុមារមានលទ្ធភាពបន្តសិក្សា ដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា ដើម្បីផ្តល់ជំនាញវិជ្ជាជីវៈផ្នែកសំអាងការ ព្រមទាំងបានធ្វើកិច្ចសន្យាជាមួយអាណាព្យាបាលរបស់កុមារទាំង៩០គ្រួសារ (ទាំងគ្រួសារទប់ស្កាត់ និងគ្រួសារកុមារដកហូត)។ **២-រដ្ឋបាលស្រុកអង្គរជុំ** បានសហការជាមួយអង្គការជំហ៊ានដំបូង ធ្វើការផ្សព្វផ្សាយដល់ក្លឹបកុមារចំនួន**០២**ឃុំ ស្តីពីផលប៉ះពាល់នៃការរៀបការវ័យក្មេង បានចំនួន **០២**លើក អ្នកចូលរួមសរុប **២៤៧**នាក់ (ស្រី **១៦២**នាក់)។

• **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បីផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍សរុបចំនួន **១.១៣៣**នាក់។

•**អង្គការមូលនិធិអេ២១** (ខេត្តសៀមរាប)៖ បានចុះអប់រំកុមារស្តីពី សុវត្ថិភាពតាមប្រព័ន្ធអនឡាញ តាមរយៈការលេងហ្គេមអប់រំមេឃ និងដី និងទប់ស្កាត់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព បានចំនួន **០៥**លើក ដែលមានកុមារចូលរួមសរុប **២២៨** នាក់ (ស្រី **១៣២**នាក់) និងបានចុះធ្វើការអប់រំកុមារសុំទាន បានចំនួន **០១**លើក ដែលមានកុមារសរុប **១៥**នាក់ (ស្រី **០៩**នាក់)។

**៤. ការលើកកម្ពស់ជីវភាព និងការផ្តល់ឱ្យមានអាជីពការងារ និងវិជ្ជាជីវៈ សម្រាប់ទីផ្សារការងារ**

៤-១-ការផ្តល់ឥណទានកម្ចីសម្រាប់បង្កើនមុខរបរការងារ

•**ក្រសួងអភិវឌ្ឍន៍ជនបទ** តាមរយៈគម្រោងឥណទានជនបទ ដែលដឹកនាំ និងត្រួតពិនិត្យដោយនាយកដ្ឋានសេដ្ឋកិច្ចជនបទ ដែលកំពុងអនុវត្តផ្ទាល់ដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត សហការជាមួយដៃគូ និង សកម្មភាពការងារឥណទាន ដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានចំនួន **៤.១៦០.៣១៤.២៧៥** រៀល (បួនពាន់មួយរយហុកសិបលានបីរយដប់បួនពាន់ពីរយចិតសិបប្រាំរៀល) ស្មើនឹង**១.០៤០.០៧៨.៥៧** ដុល្លារអាមេរិក (មួយលានសែសិបពាន់ចិតសិបប្រាំបីដុល្លារ និងហាសិបប្រាំពីរសេន)មានអ្នកខ្ចីសរុបចំនួន **៣.៥៦៣**នាក់ (ស្រី **២.៩៤៦**នាក់) នៅភូមិគោលដៅចំនួន **១៧០**ភូមិ **៦៨**ឃុំ **៣១**ស្រុក ក្នុងខេត្តគោលដៅចំនួន **១៥**ខេត្ត។ បានជួយផ្តល់នូវជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋក្នុងសហគមន៍ តាមរយៈវគ្គបណ្តុះបណ្តាលចិញ្ចឹមត្រី មាន់ ជ្រូក បណ្តុះផ្សិត ដាំដំណាំគ្រួសារ អនុវត្តកម្មវិធីផ្គត់ផ្គង់

ទឹកជនបទ កម្មវិធីថែទាំសុខភាព និងអនាម័យជនបទ កម្មវិធីអភិវឌ្ឍផ្លូវជនបទ។ ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) ការអភិវឌ្ឍភូមិចម្រុះ ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ ការបណ្តុះបណ្តាលជំនាញមូលដ្ឋានក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជពលរដ្ឋនៅជនបទ ដើម្បីកាត់បន្ថយប្រជាពលរដ្ឋចំណាកស្រុក។

៤.២-ការផ្តល់ព័ត៌មានការងារ និងបង្កើតកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ

- **ថ្នាក់ជាតិ៖**

  - **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖

    - (១)-ផ្តល់សេវាប្រឹក្សាយោបល់ អំពីអាជីពការងារ និងវិជ្ជាជីវៈដល់អ្នកមកទទួលសេវាចំនួន **៤.៩៧៧**នាក់ **(២)**-ផ្តល់កម្មវិធីតម្រង់ទិសវិជ្ជាជីវៈនៅតាមសាលាមធ្យមសិក្សាចំណេះទូទៅ **១២១**សាលា ដែលមានសិស្សសរុបចំនួន **២២.១៣៩**នាក់ (ស្រី **១០.២៨៨**នាក់), **(២)**-រៀបចំពិព័រណ៍ការងារចល័តចំនួន **៥៦**ដង ដែលមានអ្នកចូលរួមសរុបចំនួន **២ ១៦.៧០០**នាក់, **(៣)**-រៀបចំកម្មវិធីវេទិកាការងារចំនួន **២៨**ដង ដែលមានអ្នកចូលរួមសរុបចំនួន ៨.០៤៩នាក់។
    - ពង្រឹង និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈការងារដោយបាន៖ **(១)**-ផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មបានចំនួន **៦០.៨១៥**កន្លែង និងតាមប្រព័ន្ធ Online ចំនួន **១៨.៤៧៥**ដង, **(២)**-ចងក្រង និងផលិតស្លាកផ្សព្វផ្សាយចំនួន **១៥**ដង, **(៣)**-ធ្វើកម្មវិធី Roadshow និងផ្សព្វផ្សាយនៅតាមសហគមន៍ ចំនួន **៩៧**ដង មានសិស្សចំនួន **១៨.៦៧៤**នាក់ (ស្រី **៨.៩៩០**នាក់), **(៤)**-ប្រជាពលរដ្ឋ សិស្ស និស្សិតចូលប្រើប្រាស់គេហទំព័រការងារទីភ្នាក់ងារជាតិមុខរបរ និងការងារ ចំនួន **៤៣៦.២០៥**លើក និងអ្នកទទួលបានព័ត៌មានអំពីទីផ្សារការងារ តាមរយៈទំព័រ Facebook សរុបចំនួន **១១៥.០៧៨**នាក់។ និងមានអ្នកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើទូរស័ព្ទវៃឆ្លាត សរុប **១.៣៩១**នាក់។

- **ថ្នាក់ក្រោមជាតិ៖**

  - **ខេត្តបន្ទាយមានជ័យ៖** អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បើកវគ្គតម្រង់ទិស ស្តីពីធ្វើការសម្រេចចិត្តដែលប្រកបដោយសុវត្ថិភាព ដើម្បីណែនាំដល់ពលករវិលត្រឡប់មកពីថៃ និងម៉ាឡេស៊ី ចំនួន **១.៤០២**នាក់ (ស្រី**៥៥២**នាក់)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការខានុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **៨៧**ករណី(ធៀបនឹងឆមាសទី១ ឆ្នាំ២០២២ មានចំនួន **៧៤**ករណី កើនឡើងចំនួន **១៤**ករណី) ស្មើនឹង **១៧,៥៦%** ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **៩៦**នាក់/៨៣នាក់ (ស្រី **១៥**នាក់) អនីតិជន **១៥**នាក់។ ក្នុងនោះជនសង្ស័យបរទេសចំនួន **០៤**នាក់ (ស្រី **០១**នាក់) មានជនជាតិ(ចិន **០១**នាក់, ហ្វីលីពីនស្រី **០១**នាក់ អាមេរិក**០១**នាក់ និងជនជាតិវៀតណាម **០១**នាក់)។
- សង្គ្រោះជនរងគ្រោះ ចំនួន **២៨១**នាក់/**១៥៦**នាក់(ស្រី **១៧៧**នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ **៧៨**នាក់ អាយុ១៥-១៧ឆ្នាំ **២៣**នាក់ និងអាយុពី១៨ឆ្នាំឡើង **១៨០**នាក់(ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **៧០**នាក់ និងប្រគល់ឱ្យគ្រួសារ **២១១**នាក់) ក្នុងនោះចែកជា៖

## ១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ១០ករណី/១៦ករណី(ថយចុះ ០៦ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១១នាក់ (ស្រី ០២នាក់) អនីតិជន ០១នាក់ ជនបរទេស ០៣នាក់(ស្រី ០១នាក់) មានជនជាតិ ចិន ០១នាក់, ហ្វីលីពីនស្រី ០១នាក់ អាមេរិក០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៤៣នាក់(ស្រី ៤៩នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ ០៦នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុ១៨ឆ្នាំឡើង ១៣៤នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១១នាក់ និងប្រគល់ឱ្យគ្រួសារ ១៣២នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ៩ | ០១ | ០១ | ០១ | ចិន ០១ |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១០ | ០៤ | ០៤ | ០៥<br>(អនីតិជន០១) | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | ០២ | ១៣៥ | ០២ | |
| -អំពើលក់ដូរមនុស្ស | ១៤ | ០១ | ០១ | ០១ | ហ្វីលីពីន០១ |
| -ការទិញពេស្យាចារកុមារ | ៣៤ | ០២ | ០២ | ០២ | អាមេរិក០១ |
| *សរុប* | | *១០ករណី* | *១៤៣នាក់* | *១១នាក់*<br>(អនីតិជន០១) | *០៣នាក់* |

## ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ៧៧ករណី/៥៨ករណី(កើន ១៩ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៨៥នាក់(ស្រី ១៣នាក់) អនីតិជន ១៤នាក់ និងជនជាតិវៀតណាម ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៣៨នាក់(ស្រី ១៣៧នាក់) មានៈ អាយុក្រោម១៥ឆ្នាំ ៧២នាក់ អាយុ១៥-១៧ឆ្នាំ ២០នាក់ និងអាយុ១៨ឆ្នាំឡើង ៤៦នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ៥៩នាក់ និងប្រគល់ឱ្យគ្រួសារ ៧៩នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| -សញ្ញារកម្ម | ២៦ | ០២ | ២៩ | ០៤ | |
| -ស្ថានទម្ងន់ទោសនៃសញ្ញារកម្ម | ២៧ | ០៣ | ០៩ | ០៤ | |
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២៨ | ០៥ | ២២ | ០៦ | |
| -បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ៣៣ | ០១ | ០៣ | ០២ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ៣៩ | ០៥ | ០៥ | ០៥<br>(អនីតិជន០១) | |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ៤១ | ០៣ | ០៣ | ០៣ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤២ | ៣៩ | ៣៩ | ៤២<br>(អនីតិជន១២) | វៀតណាម០១ |
| -អំពើអាសប្រធាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤៣ | ១៩ | ២៨ | ១៩<br>(អនីតិជន០១) | |
| *សរុប* | | *៧៧ករណី* | *១៣៨នាក់* | *៨៥នាក់*<br>*(អនីតិជន១៤)* | *០១នាក់* |

## ២-កិច្ចការយុត្តិធម៌

### ២.១.ចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារជំនាញកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

**១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖**

សំណុំរឿងសរុបមានចំនួន **២០៩** (ក្នុងនោះសំណុំរឿងចាស់មានចំនួន **៣១**)

-**ជនរងគ្រោះ** សរុបចំនួន **១៨៨**នាក់(ស្រី **១៥៦**នាក់) ក្នុងនោះអនីតិជន **១២៣**នាក់ (ស្រី **១១៦**នាក់) និងជនបរទេស **២២**នាក់(ស្រី **០៤**នាក់)។

-**ជនល្មើស** សរុបមានចំនួន **២៧២**នាក់ (ស្រី **៣៣**នាក់) ក្នុងនោះអនីតិជន **១១**នាក់(ស្រី **០១**នាក់) ជនបរទេស **៤៧**នាក់(ស្រី **០៥**នាក់), អញ្ញាតជន **០៤**នាក់។

❖ **សំណុំរឿងចាត់ការរួច: ១៥៥**សំណុំរឿង មានដូចជា៖ បញ្ជូនទៅស៊ើបសួរ **១៤១**សំណុំរឿង បញ្ជូនរឿងទៅជម្រះ **០១**សំណុំរឿង, នីតិវិធីបង្ហាញខ្លួនភ្លាម **០១**សំណុំរឿង, តម្កល់រឿងទុកឥតចាត់ការ **១២**សំណុំរឿង, បញ្ចូលសំណុំរឿង (**គ្មាន**), ផ្ទេរសមត្ថកិច្ច(**គ្មាន**) និងកំពុងចាត់ការ **៥៤**សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោម៖

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនល្មើស | | | | | | | សំណុំរឿងចាត់ការរួច | | | | | រឿងកំពុងចាត់ការ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | អញ្ញាតជន | បញ្ជូនទៅស៊ើបសួរ | បញ្ជូនរឿងទៅជម្រះ | នីតិវិធីបង្ហាញខ្លួនភ្លាម | តម្កល់រឿងទុកឥតចាត់ការ | បញ្ចូលសំណុំរឿង | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | | |
| ២០៩ | ០៧ | ៣៦ | ០៧ | ១១៦ | ១៨ | ០៤ | ១៨៧ | ២៧ | ១០ | ០១ | ៤២ | ០៥ | ០៤ | ១៤១ | ០១ | ០១ | ១២ | ០ | ៥៤ |
| សរុប | ៤៣នាក់ | | ១២៣នាក់ | | ២២នាក់ | | ២១៤នាក់ | | ១១នាក់ | | ៤៧នាក់ | | ០៤ | | | | | | |
| សរុបរួម | ១៨៨នាក់ | | | | | | ២៧២ នាក់ (រួមទាំងអញ្ញាតជន ០៤នាក់) | | | | | | | ១៥៥ សំណុំរឿង | | | | | ៥៤ សំណុំរឿង |

**២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត៖**

សរុបមានចំនួន **២៥៥**សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់មាន **១៤៤**)

- **ជនរងគ្រោះ** ចំនួន **២៥៧**នាក់(ស្រី **១៧៩**នាក់) ក្នុងនោះអនីតិជន **១១១**នាក់ (ស្រី **១០៥**នាក់) និងជនបរទេស **៤២**នាក់(ស្រី **២៣**នាក់) ។

-**ជនត្រូវចោទ** ចំនួន **៤១៣**នាក់ (ស្រី **៧៧**នាក់) ក្នុងនោះអនីតិជន **៤០**នាក់ (ស្រី **២៦**នាក់) ជនបរទេស **៥៧**នាក់(ស្រី **០៥នាក់**), អញ្ញាតជន ០១នាក់ និងក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ **គ្មាន**។

❖ **រឿងចាត់ការរួច៖** បញ្ជូនរឿងទៅជម្រះចំនួន **៨៣**សំណុំរឿង លើកលែងចោទ **០១**សំណុំរឿង ផ្ទេរសមត្ថកិច្ច (**គ្មាន**) បណ្តឹងឧទ្ធរណ៍(**គ្មាន**) កំពុងចាត់ការ **១៧១**សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោម៖

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនត្រូវចោទ | | | | | | | | | ប្រភេទចំណាត់ការរួច | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | ក្រោមការគ្រប់គ្រងពិនិត្យតាមផ្លូវតុលាការ | | អញ្ញាតជន | បញ្ជូនរឿងទៅជំនុំជម្រះ | លើកលែងបទចោទ | ផ្ទេរសមត្ថកិច្ច | បណ្តឹង ឧទ្ធរណ៍ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ចំនួនរឿង | ចំនួនមនុស្ស | | | | | | |
| ២៥៥ | ៥៣ | ៥១ | ០៦ | ១០៥ | ១៩ | ២៣ | ២៧០ | ៤៦ | ១៤ | ២៦ | ៥២ | ០៥ | ០ | ០ | ០១ | ៨៣ | ០១ | ០ | ០ | ១៧១ |
| សរុប | ១០៤នាក់ | | ១១១នាក់ | | ៤២នាក់ | | ៣១៦នាក់ | | ៤០នាក់ | | ៥៧នាក់ | | ០ | | ០១ | | | | | |
| សរុបរួម | ២៤៧ នាក់ | | | | | | ៤១៣នាក់ (អញ្ញាតជន ០១នាក់) | | | | | | | | | ៨៤ សំណុំរឿង | | | | ១៧១ សំណុំរឿង |

៣. **ដំណាក់កាលថៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត៖**

សរុបមានចំនួន **២៤៤**សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់ **១២៥**)

- **ជនរងគ្រោះ** ចំនួន **២៨៩**នាក់ (ស្រី **១៩៩**នាក់) ក្នុងនោះអនីតិជន **១៥៧**នាក់(ស្រី **១២៨**នាក់) និងជនបរទេស **៣៧**នាក់(ស្រី **១៨**នាក់)។
- **ជនជាប់ចោទ** ចំនួន **៣៥៥**នាក់(ស្រី **៤៥**នាក់) ក្នុងនោះអនីតិជន **១៣**នាក់(ស្រី **គ្មាន**) ជនបរទេស **៨០**នាក់(ស្រី **០៧**នាក់) អញ្ញាតជន **០៣**នាក់។

❖ **សំណុំរឿងចាត់ការរួចប្រកាសសាលក្រម៖** បានជំនុំជម្រះ **១០៣**សំណុំរឿង ផ្ទេរសមត្ថកិច្ច(**គ្មាន**) **ប្រកាសសាលក្រមឱ្យ:** រួចផុតពីបទចោទ **០២**សំណុំរឿង មនុស្សចំនួន **០២**នាក់(ស្រី **គ្មាន**), **ផ្តន្ទាទោសដោយ:** ពិន័យជាប្រាក់ **០២** សំណុំរឿង ដាក់ពន្ធនាគារ **៦៣**សំណុំរឿង មនុស្សចំនួន **៧៤**នាក់(ស្រី **០៩**នាក់), **ទោសព្យួរ:** ព្យួរទោសសាកល្បង **០១** សំណុំរឿង ព្យួរទោសធម្មតា **១០**សំណុំរឿង មនុស្សចំនួន **០៩**នាក់(ស្រី **០២**នាក់), **បណ្តឹងឧបាស្រ័យ:** បណ្តឹងជំទាស់( **គ្មាន** ) បណ្តឹងឧទ្ធរណ៍(**គ្មាន**) សរុបរឿងចាត់ការរួច **១០៣**សំណុំរឿង និងកំពុងចាត់ការ **១៤១**សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោម៖

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនជាប់ចោទ | | | | | | | ប្រភេទចំណាត់ការរួច | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | អញ្ញាតជន | បញ្ជូនរឿងទៅជំនុំជម្រះ | ផ្ទេរសមត្ថកិច្ច | ប្រកាសសាលក្រម | | | | | | | | | | | បណ្តឹងឧបាស្រ័យ | | សរុបចាត់ការរួច | រឿងកំពុងចាត់ការ |
| | | | | | | | | | | | | | | | | រួចផុតបទចោទ | | | ផ្តន្ទាទោស | | | | ទោសព្យួរ | | | | | | | |
| | | | | | | | | | | | | | | | | | ចំនួនមនុស្ស | | | | ចំនួនមនុស្ស | | | | ចំនួនមនុស្ស | | | | | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | សំណុំរឿង | សរុប | ស្រី | ពិន័យជាប្រាក់ | ដាក់ពន្ធនាគារ | សរុប | ស្រី | ទោសព្យួរសាកល្បង | ទោសព្យួរធម្មតា | សរុប | ស្រី | បណ្តឹងជំទាស់ | បណ្តឹងឧទ្ធរណ៍ | | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុប ២៨៤ | ៤២ | ៥៣ | ២៩ | ១២៨ | ១៩ | ១៨ | ២២៤ | ៣៨ | ១៣ | ០ | ៧៣ | ០៧ | ០៣ | ១០៣ | ០ | ០២ | ០២ | ០ | ០២ | ៦៣ | ៧៤ | ០៩ | ០១ | ១០ | ០៩ | ០២ | ០ | ០ | ១០៣ | ១៦១ |
| | ៩៥ | | ១៥៧ | | ៣៧ | | ២៦២ | | ១៣ | | ៨០ | | ០៣ | | | | | | | | | | | | | | | | ២៨៤ សំណុំរឿង | |
| | ២៨៩នាក់ | | | | | | ៣៥៥ នាក់ (អញ្ញាតជន ០៣នាក់) | | | | | | | | | | | | | | | | | | | | | | | |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន( ផ្លូវគោក និងផ្លូវអាកាស )ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់ (ផ្លូវគោក និងផ្លូវអាកាស)

• **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ, អគ្គស្នងការដ្ឋាននគរបាលជាតិ, អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត** ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន **១២.៦៤១**នាក់( ប្រុស **៦.៤១២**នាក់ ស្រី **៤,៧៤២**នាក់ កុមារា **៨១៩**នាក់ កុមារី **៦៦៨**នាក់ ) មានសកម្មភាពដូចជា៖

**១-នាយកដ្ឋានគាំពារជនរងគ្រោះ** នៃក្រសួង ស.អ.យ បានទទួល ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាតាមផ្លូវអាកាស សរុប **១៧៩**នាក់( បុរស ០៣នាក់ ស្រី **១៧៥**នាក់ កុមារី ០១នាក់ ) មកពីប្រទេសចិន **១៧២**នាក់ ( ស្រី **១៧០**នាក់ ) ម៉ាឡេស៊ី ០៧នាក់( ស្រី ០៦នាក់ ) និងបានសម្ភាសកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ( ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ **១៦៦**នាក់ ជួញដូរកម្លាំងពលកម្ម ០៩នាក់ ងាយរងគ្រោះ ០៤នាក់ ក្រោយពីសម្ភាសកំណត់អត្តសញ្ញាណរួច ក៏បញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។

**២-មណ្ឌលសំចតប៉ោយប៉ែត** បានទទួលពលករចំណាកស្រុកពីប្រទេសថៃតាមផ្លូវគោកចំនួន **៥.៦៩៧**នាក់ កំណត់( ប្រុស **៣.០៩៨**នាក់ ស្រី **១.៩៣៧**នាក់ កុមារា **៣៤៧**នាក់ កុមារី **៣១៥**នាក់ ) ក្នុងនោះបានសម្ភាសអត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះ ចំនួន **២១៤**នាក់( ប្រុស **១១**នាក់ ស្រី **២០០**នាក់ កុមារី ០៣នាក់ កុមារី **៤៤**នាក់ ) ក្នុងនោះរកឃើញ៖ ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ **១១៩**នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម **២៨**នាក់ រំលោភបំពានផ្លូវភេទ **៤៦**នាក់ ងាយរងគ្រោះ **២១**នាក់ និងពលករចំនួន **៤៥៨**នាក់( ប្រុស **២២២**នាក់ ស្រី **១៨៣**នាក់ កុមារា **២៤**នាក់ កុមារី **២៩**នាក់ ) បានមកបន្តធ្វើប័ណ្ណព្រំដែន ក្រោយពីសម្ភាសកំណត់អត្តសញ្ញាណរួច ក៏បញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ ចំនួន **២១៤**នាក់។

**៣-បានទទួល** ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ពីកម្លាំងនគរបាលនៅក្នុងស្រុក និងបានសហការជាមួយអង្គការដៃគូ សរុបចំនួន **៣៥**នាក់( ប្រុស ០៨នាក់ ស្រី **២៥**នាក់ កុមារី ០២នាក់ )

**៤-មណ្ឌលទទួលពលករកំរៀង របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានទទួលពលករសរុបចំនួន **៣.៦៨៧**នាក់ ( ប្រុស **១.៦៦៤**នាក់ ស្រី **១.៥៩៥**នាក់ ) កុមារា **២៤៣**នាក់ កុមារី **១៨៥**នាក់ )ក្នុងនោះមាន៖ ស្ត្រីមានកូនតូច **៧៨**នាក់ ស្ត្រីមានផ្ទៃពោះ **៩១**នាក់ និងជនពិការ **២៥**នាក់ ( ស្រី ០៥នាក់ )។

**៥-ស្នងការដ្ឋាននគរបាលខេត្ត** ចំនួន ០៣ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ក្នុងនោះមាន(ច្រកចាំយាម ច្រកធម្មជាតិ) និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម បានចំនួន **១៧៨**លើក សរុបមនុស្សចំនួន **៣.០៤៣**នាក់ (ប្រុស **១.៦៣៩**នាក់ ស្រី **១.០១០**នាក់ កុមារ **២២៩**នាក់ កុមារី **១៦៥**នាក់) ក្នុងនោះមាន៖

- **ខេត្តបន្ទាយមានជ័យ** ចំនួនៈ **១៤៧**លើក មនុស្សចំនួនៈ**២,៨៣១**នាក់(ប្រុស **១.៥៤៩**នាក់ ស្រី **៩៥៨**នាក់, កុមារ **១៩០**នាក់កុមារី **១៣៤**នាក់)។
- **ខេត្តកោះកុង** ចំនួន **២៥**លើក មនុស្សចំនួន **៧៨**នាក់(ប្រុស **៤៧**នាក់ ស្រី **៣១**នាក់)។
- **ខេត្តស្វាយរៀង** ចំនួន ០៦លើក មនុស្សចំនួន **១១៣**នាក់(ប្រុស **៤៣**នាក់ស្រី **២១**នាក់ កុមារ **៣៩**នាក់ កុមារី **៣១**នាក់)។

### ១.២. ការបិទករណី

• **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយអង្គការដៃគូ បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន **១១៩**នាក់(ប្រុស ០៦នាក់ ស្ត្រី **១១៣**នាក់) មានៈ (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ០៤នាក់ ជួញដូរ និងរំលោភបំពានផ្លូវភេទ **៥០**នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម **២៣**នាក់ និងងាយរងគ្រោះ ៤២នាក់។

## ២. កិច្ចការពារជនរងគ្រោះ ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

• **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅស្តារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូ សរុប **២១៤**នាក់(ប្រុស **១១**នាក់ ស្រី **២០០**នាក់ កុមារី ០៣នាក់) ក្នុងនោះករណី(អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ **១១៩**នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម **២៨**នាក់ ជួញដូរ និងរំលោភបំពានផ្លូវភេទ **៤៦**នាក់ និងងាយរងគ្រោះ **២១**នាក់)។ ក្នុងនោះបញ្ជូនទៅអង្គការដៃគូចំនួន **២១៤**នាក់ មានអង្គការ៖ (កម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC), មិត្តសំឡាញ់, ការីតាសកម្ពុជា, រតនៈអ៊ីនធើណេសិនណល, បេសកម្មយុត្តិធម៌អន្តរជាតិ(IJM), សង់ត្រាល់ សម្ព័ន្ធចាប់ដៃ, និងអង្គការហាកា។

## ៣.ការធ្វើសមាហរណកម្ម

### ៣-១-ការធ្វើសមាហរណកម្មពលករខ្មែរដែលជាជនរងគ្រោះ និងងាយរងគ្រោះ

• **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប **១៣៨**នាក់(ប្រុស **១៥**នាក់ ស្រី **១២៣**នាក់) ក្នុងនោះករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ **៥៣**នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម **១២**នាក់ ជួញដូរ និង រំលោភបំពានផ្លូវភេទ **៥៩**នាក់ និងងាយរងគ្រោះ **១៤**នាក់ ដោយមានការចូលរួមសហការគាំទ្រពីអង្គការដៃគូ។

➢ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន **១៨៧**នាក់(ប្រុស **២៥**នាក់ ស្ត្រី **១៦២**នាក់ ) កេងប្រវ័ញ្ចកម្លាំងពលកម្ម **៥២**នាក់ ជួញដូរ និង រំលោភបំពានផ្លូវភេទ **១៣១**នាក់ និងងាយរងគ្រោះ ០៤នាក់ ត្រូវបានបន្តតាមដានក្រោយពីធ្វើសមាហរណកម្មរួច ដោយមានកិច្ចសហការជាមួយអង្គការដៃគូ។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ ក្រសួង ស្ថាប័ន និង គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត(គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយ អង្គការដៃគូពាក់ព័ន្ធ រៀបចំបើកវគ្គបណ្តុះបណ្តាលចំនួន **៦៧៥**វគ្គ មានសិក្ខាកាមចូលរួមចំនួន **២៧.៨១៦**នាក់ ក្នុងនោះមានស្ត្រី **១១.៧៣៤**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងខាងក្រោម៖

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ បានរៀបចំបើកវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្តកសាងសមត្ថភាពដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ស្តីពី៖ **១**-ការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅបរទេស។ **២**-ជំនាញទន់ និងការត្រៀមលក្ខណៈសម្បត្តិក្នុងការស្វែងរកការងារធ្វើ។ **៣**-ការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅបរទេស។ **៣**-នីតិវិធីនៃការចុះយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម។ **៤**-ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកខុសច្បាប់ និងកិច្ចការពារកុមារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ។ **៥**-ការមិនបង្កហានិភ័យ និងការគ្រប់គ្រងករណីសម្រាប់ពលករនៅតាមភូមិ/ឃុំ/ស្រុក។ **៦**-កិច្ចការពារកុមារ ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ **៧**-នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការសម្ភាសបែបកោសល្យវិច័យ។ **៨**-ការវាយតំលៃតាមដានការចល័តរបស់ជនទេសន្តរប្រវេសន៍ តាមព្រំដែនកម្ពុជា-ឡាវ។ **៨**-នីតិវិធីគ្រប់គ្រងករណី និងការស្វែងយល់ពីការប៉ះទង្គិចផ្លូវចិត្តជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥២៧ | ២២,២៦៦ | ៩,២៥៦ |
| ក្រសួងកិច្ចការនារី សហការជាមួយអង្គការ (ILO, WOMEN &IOM) | ០៣ | ១៦៥ | ១១០ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការ (ASEAN-ACT) | ០២ | ៦៧ | ២៨ |
| ក្រសួងធម្មការ និងសាសនា | ០៤ | ៤៤៧ | ១៥៦ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ២៧ | ៤៧៩ | ៨៩ |
| សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ថ្នាក់កណ្តាល | ០២ | ៨១ | ២៩ |
| អគ្គស្នងការដ្ឋាន សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ | ០២ | ៦៨ | ៥៥ |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយអង្គការដៃគូ អង្គការកោរីតាស និងអង្គការអេ២១ | ០៥ | ១៩០ | ៤៨ |
| កាកបាទក្រហម | ០១ | ២៥ | ០៩ |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តបាត់ដំបង | ០៤ | ១៧៤ | ៥៤ |
| ខេត្តព្រះវិហារ | ០១ | ២៨ | ១៨ |
| ខេត្តកំពង់ធំ | ០២ | ១១៧ | ៥១ |
| ខេត្តស្វាយរៀង | ២៨ | ៥៦៨ | ៣១៦ |

| | | | |
|---|---|---|---|
| ខេត្តស្ទឹងត្រែង | ០៧ | ២១៤ | ១៣០ |
| ខេត្តក្រចេះ | ០១ | ៣២ | ១០ |
| ខេត្តកំពង់ចាម | ០៩ | ២៨៧ | ២៨២ |
| ខេត្តរតនគិរី | ០១ | ៥៩ | ៥៣ |
| ខេត្តមណ្ឌលគិរី | ០១ | ៤២ | ៣៤ |
| ខេត្តតាកែវ | ០១ | ៧០ | ០៦ |
| **អង្គការដៃគូ** | | | |
| អង្គការសម្ព័ន្ធចាប់ដៃ(ខេត្តកំពង់ចាម) | ០២ | ៥២ | ៣៩ |
| អង្គការLSCW និងអង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍(ខេត្តកំពង់ចាម) | ០១ | ៤៦ | ០៨ |
| អង្គការ IJM (ត្បូងឃ្មុំ) | ០១ | ៥០ | ០៧ |
| អង្គការសម្ព័ន្ធចាប់ដៃ(ត្បូងឃ្មុំ) | ០១ | ៣៥ | ២៣ |
| អង្គការ IJM(ខេត្តបន្ទាយមានជ័យ) | ០១ | ៨០ | ២៨ |
| អង្គការ IJM(ខេត្តកំពត) | ០១ | ៧៨ | ២៣ |
| អង្គការ IJM(ខេត្តព្រះសីហនុ) | ០១ | ៤៧ | ០៩ |
| អង្គការមូលនិធិអេ២១ (ខេត្តបាត់ដំបង) | ០៤ | ១៩៣ | ៨៨ |
| អង្គការសាម៉ារីតាន់ភឺស (ខេត្តបាត់ដំបង) | ០៧ | ៤៥៥ | ២៣៣ |
| អង្គការកល្យាណមិត្ត (ខេត្តសៀមរាប) | ០១ | ៣០ | ០៣ |
| អង្គការម្លប់ឬស្សី (ខេត្តកំពង់ឆ្នាំង) | ០១ | ៥៤ | ៤៩ |
| អង្គការ UNFPA (ខេត្តព្រះវិហារ) | ១០ | ៣៤ | ១៦ |
| អង្គការ ADRA (ខេត្តព្រះវិហារ) | ០១ | ១៨១ | ២៩ |
| អង្គការមូលនិធិហាកា(ខេត្តតាកែវ) | ០១ | ៨៨ | ៥០ |
| ខេត្តសៀមរាប សហការជាមួយអង្គការអេ២១, អង្គការ(IJM), អន្តរជាតិហាការ | ១៥ | ៩៨៥ | ៣៧៨ |
| ខេត្តបន្ទាយមានជ័យ សហការជាមួយអង្គការ MOI | ០១ | ២៩ | ១៧ |
| សរុប | **៦៧៥វគ្គ** | **២៧.៨១៦នាក់** | **១១.៧៣៤នាក់** |

## ២. សិក្ខាសាលា

ក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំសិក្ខាសាលាដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ បានចំនួន **៣១៧**វគ្គ មានសិក្ខាកាមចូលរួមចំនួន **១៦.១០៩**នាក់ ក្នុងនោះមានស្ត្រី **១.៧៤៦**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| |
|---|
| ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ បានរៀបចំសិក្ខាសាលា ដើម្បីពង្រឹងសមត្ថភាពការងារដល់មន្ត្រីពាក់ព័ន្ធ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ស្តីពី៖ ការរៀបចំសៀវភៅផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីសុខភាពជនទេសន្តរប្រវេសន៍ ២០២៣-២០២៥ ១-«សាសនិកចូលរួមប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប»។ ២-«ការគូសផែនទីប្រជាជនបំលាស់ចល័ត» ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង់ប្រជាជនបំលាស់ទីធ្វើចំណាកស្រុក ផែនការអាជីព និងជ្រើសរើសជំនាញការងារសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ និងនិស្សិតនៅ |

គ្រឹះស្ថានអប់រំ។ ៣-សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។ ៤-ការជំរុញការចូលរួមរបស់ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។ ៥-បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ ៦-លើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ។ ៧-សិទ្ធិកុមារ និងច្បាប់នានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។ ៨-កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ៩-ស្តីពីការផ្សព្វផ្សាយលើការវិភាគស្ថានភាពកុមារ និងក្មេងជំទង់នៅកម្ពុជា និងការអន្តរាគមន៍ដ៏មានសក្តានុពល ៩-បង្កើតជាតុចូលលើឧបសម្ព័ន្ធ នៃផែនការសកម្មភាពនៃនីតិវិធីប្រតិបត្តិបទដ្ឋាន សម្រាប់ការគ្រប់គ្រងករណីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

| សកម្មភាពរៀបចំសិក្ខាសាលា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២៩១ | ១៤.៩៧៥ | ១.២៥៧ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការ IOM និងអង្គការតេនៈអ៊ីនធើណេសិនណល | ០៤ | ១១៥ | ៥៩ |
| ក្រសួងសុខាភិបាលសហការជាមួយអង្គការ IOM | ០១ | ៦៧ | ២៤ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០៣ | ៨៩ | ២៨ |
| ក្រសួងទេសចរណ៍ | ០២ | ១៤៣ | ៧៣ |
| **ថ្នាក់ក្រោមជាតិ** | | | |
| អង្គការ ILO (ខេត្តសៀមរាប) | ០៥ | ១៧២ | ៨៤ |
| អង្គការហាការ (ខេត្តសៀមរាប) | ០១ | ៤០ | ២២ |
| អង្គការជេហានថ្មីជំបូងកម្ពុជា (ខេត្តសៀមរាប) | ០៣ | ១១៤ | ៥៤ |
| អង្គការសម្ព័ន្ធចាប់ដៃ(ខេត្តកំពង់ចាម) | ០១ | ៤៣ | ១៥ |
| អង្គការ UNICEF | ០១ | ៧០ | ២៣ |
| ខេត្តបន្ទាយមានជ័យ សហការជាមួយអង្គការបេសកកម្មអន្តរជាតិ IJM | ០១ | ១០៧ | ៣៥ |
| ខេត្តកណ្តាល សហការជាមួយអង្គការក្តីសង្ឃឹម និងយុត្តិធម៌ | ០៤ | ១៧៤ | ៧២ |
| **សរុប** | **៣១៧លើក** | **១៦.១០៩នាក់** | **១.៧៤៦នាក់** |

## ខ. កិច្ចប្រជុំ សន្និសីទ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

#### ១.១. កិច្ចប្រជុំក្នុងប្រទេស

សមាជិកនៃគ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំកិច្ចប្រជុំដើម្បីពង្រឹងសមត្ថភាព ដល់មន្ត្រីពាក់ព័ន្ធ សរុបចំនួន **៣០០**លើក មានអ្នកចូលរួមចំនួន **១២.០៨៧**នាក់ ក្នុងនោះមានស្ត្រី **៦.០១៥**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ បានរៀបចំកិច្ចប្រជុំពិភាក្សា ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ដើម្បីពង្រឹងសមត្ថភាពការងារដល់មន្ត្រីពាក់ព័ន្ធ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពី៖ ១-លើផែនការសកម្មភាពសម្រាប់អនុវត្ត «នីតិវិធីប្រតិបត្តិស្តង់ដា ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ និងពិនិត្យឡើងវិញនូវឧបសម្ព័ន្ធ ដែលបានពិភាក្សារួច នៃផែនការសកម្មភាពនៃនីតិវិធីប្រតិបត្តិបទដ្ឋាន (SOP) ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស»។ ២-ការពិនិត្យនិងពិភាក្សារបាយ

ការណ៍សិក្សារៀបចំដោយវិទ្យាស្ថានអភិវឌ្ឍន៍បរទេស (ODI) តាមប្រព័ន្ធអនឡាញ។ **៣**-ការកែសម្រួលរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅឆ្នាំ២០២៣។ ៤-ពិភាក្សាអំពីផែនការសកម្មភាពដែលត្រូវអនុវត្តដោយអង្គការដៃគូលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣។ **៥**-កិច្ចសហការ សម្រាប់ការអនុវត្តគម្រោងបង្ការទប់ស្កាត់ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស។ ១២-វាយតម្លៃពាក់កណ្ដាលអាណត្តិ ពីលទ្ធផលការងារ បញ្ហាប្រឈម និងលើកផែនការបន្តឆ្នាំ២០២៣។ **៦**-បូកសរុបរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ២០២២។ **៧**-ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ។ ៨-ពិនិត្យវឌ្ឍនភាព នៃការគ្រប់គ្រងមណ្ឌលទទួលពលករកំរៀង។ **៩**-លទ្ធផល នៃការសិក្សាស្រាវជ្រាវ និងវិភាគអំពីស្ថានភាពអាជីវកម្មផ្លូវភេទលើកុមារ។ **១០**-ត្រៀមរៀបចំបូកសរុបរបាយការណ៍ឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០២៣។ **១១**-ការត្រៀមរៀបចំទិវាជាតិអន្តរសានាប្រឆាំងការជួញដូរមនុស្សលើកទី៧ ឆ្នាំ២០២៣។ ១២-សម្រាប់ការគ្រប់គ្រងករណីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។ ១១-ដើម្បីដោះស្រាយបញ្ហាពលករដែលកំពុងស្នាក់នៅដែលគ្មានឯកសារ និងកំពុងប្រើប្រាស់ឯកសារធ្វើការងារដែលផុតសុពលភាព នៅប្រទេសថៃ។

| សកម្មភាពរៀបចំកិច្ចប្រជុំរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ៥៩ | ៤៥៧ | ២១៣ |
| ក្រសួងកិច្ចការនារីសហការជាមួយអង្គការ (ILO, WOMEN &IOM) | ០៥ | ៩៩ | ៤១ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការ IOM | ០១ | ១៩ | ០៨ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០៤ | ១១៣ | ៣៦ |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តបន្ទាយមានជ័យ | ០៣ | ២០០ | ៦៨ |
| ខេត្តបាត់ដំបង | ០៣ | ២១៧ | ៣៧ |
| ខេត្តសៀមរាប | ៤៤ | ១.៣១៥ | ៥៧២ |
| ខេត្តឧត្តរមានជ័យ | ០៣ | ២៦ | ០៨ |
| ខេត្តស្ទឹងត្រែង | ៧ | ២៨ | ១៦ |
| ខេត្តកំពង់ចាម | ០៥ | ៥៥ | ២២ |
| ខេត្តត្បូងឃ្មុំ | ២៥ | ៦.១៦៩ | ៣.៣៦១ |
| ខេត្តស្វាយរៀង | ០១ | ៥៧ | ២៤ |
| ខេត្តកណ្ដាល | ៤៥ | ១.២២១ | ៧១៨ |
| ខេត្តព្រៃវែង | ០៧ | ៦៩៦ | ២៣១ |
| ខេត្តកំពង់ស្ពឺ | ០៤ | ១៤៧ | ៨៧ |
| ខេត្តតាកែវ | ០៧ | ១៧០ | ៩៨ |
| ខេត្តកែប | ០៣ | ៣៦ | ១៨ |
| ខេត្តកំពត | ៤៦ | ៤៩៥ | ២៥៧ |
| ខេត្តកំពង់ឆ្នាំង | ២៥ | ៣៥៦ | ១២៥ |
| ខេត្តរតនគិរី | ០១ | ១៤ | ០៥ |
| ខេត្តមណ្ឌលគិរី | ០២ | ១៧ | ០៨ |
| អង្គការ IOM(ខេត្តបន្ទាយមានជ័យ) | ០១ | ៣៥ | ១១ |

| | | | |
|---|---|---|---|
| អង្គការ ILO (ខេត្តបាត់ដំបង) | ០១ | ៤៤ | ២២ |
| អង្គការ IOM សហការជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ | ០១ | ៤៧ | ១១ |
| អង្គការ Terre des Hommed សហការជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងអង្គការ UNFPA | ០១ | ២៦ | ០៩ |
| អង្គការ IJM សហការជាមួយក្រសួង ស.អ.យ | ០២ | ២៨ | ០៩ |
| **សរុប** | **៣០០លើក** | **១២.០៨៧នាក់** | **៦.០១៥នាក់** |

**១.២.កិច្ចនៅក្រៅប្រទេស**

• **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំគណៈប្រតិភូ អញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេស និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកិច្ច នៃសន្និសីទ Bali Process ដែលមានវេទិការដ្ឋាភិបាល និងវិស័យឯកជន ពិភាក្សាអំពីទម្រង់ថ្មី នៃអំពើរត់ពន្ធមនុស្ស ការកេងប្រវ័ញ្ចពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស (Bali process Conference: the government and Business Forum on People Smuggling Forced Labor and Drafficking in persens) ដែលផ្សារភ្ជាប់ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទំនើប និងពិបាកស្វែងរកជនល្មើសដើម្បីផ្ដន្ទាទោស ដែលធ្វើឡើងនៅប្រទេសអូស្ត្រាលី។

• **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានដឹកនាំក្រុមការងារចូលរួមកិច្ចប្រជុំបច្ចេកទេសស្តីពីការធ្វើបច្ចុប្បន្នភាពលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

• **ខេត្តមណ្ឌលគិរី** លោកស្រីស្នងការរង បានដឹកនាំក្រុមការងារយេនឌ័រ ចូលរួមប្រជុំស្តីពីកិច្ចសហប្រតិបត្តិការបង្ការ បង្ក្រាបបទល្មើសជួញដូរមនុស្ស ការរំលោភបំពានលើស្ត្រី និងកុមារ ជាមួយក្រុមការងារយេនឌ័រ នៅខេត្តដាក់ឡាក់ ប្រទេសវៀតណាម។

**២. ទស្សនកិច្ច**

▪ **នៅក្នុងប្រទេស**

• **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំប្រតិភូ មកពីប្រទេសស្វីសទៅធ្វើទស្សនកិច្ចនៅមណ្ឌលកំរៀង និងច្រកទ្វារព្រំដែនអន្តរជាតិដូង។ សមាសភាពចូលរួមមាន លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ លោក **ភីធី លែក** ប្រធានអង្គការការីតាស់ស្វីស លោកស្រី **ម៉ារៀន ម៉ាត់** តំណាងម្ចាស់ជំនួយនៃអង្គការ ការីតាស់ស្វីស ព្រមទាំងសហការី។

▪ **នៅក្រៅប្រទេស**

• **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ អមដំណើរដោយលោកស្រីវរសេនីយ៍ឯក **ថោង សុវត្ថិ** អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ អញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលអូស្ត្រាលីប្រឆាំងការកេងប្រវ័ញ្ចកុមារ(ACCCE) នៅប្រទេសអូស្ត្រាលី ដើម្បីសិក្សាស្វែងយល់អំពីមជ្ឈមណ្ឌលនេះ ដែលប្រតិបត្តិការដោយនគរបាលសហព័ន្ធអូស្ត្រាលី(AFP) គឺជាស្ថាប័នថ្នាក់ជាតិមួយធ្វើការងារផ្តោតលើការប្រឆាំងរាល់ទម្រង់នៃការកេងប្រវ័ញ្ចកុមារ និងមានគាំទ្រដោយស្ថាប័នមានសមត្ថកិច្ច ក្នុងការអនុវត្តសកម្មភាពបញ្ឈប់ និងផ្តន្ទាទោសបទល្មើសកេងប្រវ័ញ្ចកុមារ និងសង្គ្រោះជនរងគ្រោះឱ្យផុតពីគ្រោះថ្នាក់។

៣. ជំនួបពិភាក្សាការងារ

▪ ថ្នាក់ជាតិ

• **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយ៖ **១**-លោកស្រីបណ្ឌិត Brandais York ទីប្រឹក្សានៃអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដើម្បីសំណេះសំណាល និងសាកសួរព័ត៌មានពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **២**-លោក David និងកញ្ញា Rose ដែលមានការិយាល័យគាំទ្រតំបន់របស់ Bali Process នៅទីក្រុងបាងកក ដើម្បីពិភាក្សាលើសេចក្តីត្រូវការក្នុងការគាំទ្រពី Bali Process ជាពិសេសការបណ្តុះបណ្តាលមន្ត្រីមានសមត្ថកិច្ច ស្តីពីជំនាញពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឬការងារពាក់ព័ន្ធនឹងវិធានការផ្សេងៗ និងជាកិច្ចសហការក្នុងតំបន់ជាដើម។ **៣**-អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) និងអង្គការ IJM លើកម្មវិធីបណ្តុះបណ្តាលការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ **៤**-អង្គការការីតាសស្វីស ស្តីពីការងារពាក់ព័ន្ធនឹងការប្រឆាំងការជួញដូរមនុស្ស ជាពិសេសគម្រោងសុវត្ថិភាពទេសន្តរប្រវេសន៍នៅកម្ពុជា។ **៥**-អង្គការអេ២១ ស្តីពីគម្រោងថតវីដេអូឯកសារអប់រំ ពាក់ព័ន្ធស្ថានភាពរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **៦**-អង្គការ World Hope International ដើម្បីពិភាក្សាអំពីការងារប្រឆាំងការជួញដូរមនុស្ស ដោយមានវត្តមាន លោកស្រី Emelita S. Goddard នាយកអង្គការ World Hope International ប្រចាំនៅកម្ពុជា លោក Sam Schleipman ប្រធានផ្នែកអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ និងមន្ត្រីជាន់ខ្ពស់ផ្នែកត្រួតពិនិត្យ និងវាយតម្លៃ។

• **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានទទួលជួបពិភាក្សាការងារជាមួយ៖ **១**-លោក **ម៉ាក់ ថេយ័លីរ៍** ប្រធានអង្គការវីនរ៉ក់អន្តរជាតិនៅកម្ពុជា លើកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តផែនការសកម្មភាពនៃអនុស្សរណៈយោគយល់ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ **២**-លោកស្រី Sarah Lou Arriola ប្រធានអង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីការអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការកសាងជំនាញនិងលើកកម្ពស់ការរកការងារឱ្យធ្វើនៅបរទេស (PROMISE)ដំណាក់កាលទី១ និងដំណាក់កាលទី២ ។

• **ក្រសួងកិច្ចការនារី៖** បានទទួលជួបពិភាក្សាការងារជាមួយលោកសាស្ត្រាចារ្យ Sheldon Zhang នាយកមហាវិទ្យាល័យផ្នែកឧក្រិដ្ឋកម្ម និងយុត្តិធម៌នៃសាកលវិទ្យាល័យ University of Massachusetts និងលោកស្រី Rumi Kato Price សាស្ត្រាចារ្យមហាវិទ្យាល័យចិត្តវិទ្យា នៃមហាវិទ្យាល័យសុខាភិបាល សាកលវិទ្យាល័យ Washington University in St. Louis. ក្នុងការប្រមូលទិន្នន័យដើម្បីរៀបចំគម្រោងស្នើសុំថវិកាពីរដ្ឋាភិបាលសហរដ្ឋអាមេរិកពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ក្នុងគោលបំណងរៀបចំគម្រោងស្នើសុំថវិកាពីរដ្ឋាភិបាលសហរដ្ឋអាមេរិក សម្រាប់ការអនុវត្តកិច្ចអន្តរាគមន៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ និងពិនិត្យលទ្ធភាពក្នុងការបង្កើតនូវប្រព័ន្ធត្រៀមបម្រុងទុកមុន ដើម្បីឆ្លើយតបនឹងអំពើជួញដូរមនុស្សនៅពេលមានវិបត្តិដូចជាគ្រោះមហន្តរាយ និងការរីករាលដាលនៃជំងឺឆ្លងជាដើម ដោយជ្រើសរើសយកខេត្តស្ថិតនៅជុំវិញបឹងទន្លេសាបជាខេត្តគោលដៅ។

▪ ថ្នាក់ក្រោមជាតិ

• **ខេត្តបន្ទាយមានជ័យ៖** ក-លោកស្រី ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាជាមួយ៖ **១**.តំណាងអង្គការអន្តរជាតិ ទេសន្តរប្រវេសន្ត (IOM) ទៅលើការត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ពង្រឹងសុវត្ថិភាព សុខភាពតាមរយៈការធ្វើផែនទីប្រជាជនចល័តក្នុងតំបន់ និងអនុតំបន់មេគង្គ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងពលករចំណាកស្រុក។


ដដ

២.តំណាងមន្ទីរធម្មការ និងសាសនា ដើម្បីត្រៀមរៀបចំកម្មវិធីអន្តរសាសនាផ្សព្វផ្សាយស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមប្រធានបទ «រួមគ្នាបញ្ឈប់ ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើគ្រប់រូបភាព»។ **ខ**-ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលទស្សនៈកិច្ច និងសម្តែងការគួរសម្យពីអង្គការកុមារឥតព្រំដែនអន្តរជាតិ ដើម្បីសិក្សាពីកិច្ចសហការផ្តល់សេវាជូនកុមារ ពីការធ្វើចំណាកស្រុក និងកុមារវិលត្រឡប់ពីប្រទេសថៃ។

**•ខេត្តបាត់ដំបង៖** បានជួបពិភាក្សាជាមួយអង្គការសាម៉ារីតាន់គីសសង្គ្រោះអន្តរជាតិ ក្នុងគោលបំណងផ្តល់នូវធាតុចូលសំខាន់ៗក្នុងការធ្វើយុទ្ធសាស្ត្រ៥ឆ្នាំ (២០២៣-២០២៨) ដើម្បីចូលរួមទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ និងការរំលោភបំពានលើយេនឌ័រ នៅសាលាខេត្តបាត់ដំបង។

**•ខេត្តសៀមរាប៖** ក/លោកស្រី អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំក្រុមការងារ ជួបពិភាក្សាការងារជាមួយ៖ **១**.អង្គការយូនីសេហ្វប្រចាំកម្ពុជា ស្តីពីកិច្ចការពារកុមារ។ **២**-ជាមួយអង្គការមូលនិធិអេ២១ និងអង្គការជីវិតនៅកម្ពុជា ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋាន ស្តីពីច្បាប់យុត្តិធម៌អនីតិជន ការកំណត់អត្តសញ្ញាណជនរងគ្រោះ កិច្ចការពារកុមារ និងការផ្តល់សេវាសមស្របដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ **៣**.អង្គការអន្តរជាតិខាងការងារ(ILO) ស្តីពីការអនុវត្តកម្មវិធីនានារបស់ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ លើការផ្តល់ភាពអង់អាចទៅដល់ពលករទេសន្តរប្រវេសន៍។ **៤**-អ្នកជំនាញការជប៉ុន (ទីប្រឹក្សាគម្រោងប្រចាំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ស្តីពីការផ្តល់សេវាជនរងគ្រោះដោយផ្តោតលើការកំណត់អត្តសញ្ញាណ ការការពារ និងការវាយតម្លៃអំពីតម្រូវការ និងវិសាលភាពសម្រាប់ការកែសម្រួលគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណ និងការកសាងយន្តការបញ្ជូន។ ខ/មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជួបពិភាក្សាការងារជាមួយអង្គការអន្តរជាតិការងារ (ILO) ក្នុងការផ្តល់បទសម្ភាសន៍លើបទពិសោធន៍ នៃការផ្តល់សេវារបស់មជ្ឈមណ្ឌលទេសន្តរប្រវេសន៍ (កម្មវិធីសុវត្ថិភាព និងយុត្តិធម៌) និងចុះធ្វើបទសម្ភាសន៍ជាមួយពលករទេសន្តរប្រវេសន៍ខុសច្បាប់ជាស្ត្រី ដើម្បីចងក្រងព័ត៌មានសម្រាប់ធ្វើការចែករំលែកទៅដល់ប្រជាពលរដ្ឋ អំពីហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ដើម្បីស្វែងរកការងារធ្វើ។

**•ខេត្តកោះកុង៖** លោក **ស្រេង ហុង** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារស្តីពី យុត្តិធម៌សម្រាប់ពលករចំណាកស្រុកក្នុងវិស័យនេសាទ និងកែច្នៃម្ហូបអាហារ (JMFS) ជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី នៅសាលប្រជុំសាលាខេត្ត។

**•ខេត្តប៉ៃលិន៖** លោកជំទាវ **បាន ស្រីមុំ** អភិបាលខេត្ត បានអនុញ្ញាត និងទទួលជួបពិភាក្សាការងារជាមួយ៖ **១**-លោកវរសេនីយ៍ឯក **ម៉ែទ្រី ប៊ិតបុរី** មេបញ្ជាការយោធា ខេត្តចាន់បុរី ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងបង្កើនទំនាក់ទំនងល្អ រវាងខេត្តប៉ៃលិន និងខេត្តចាន់បុរី។ **២**-ប្រតិភូថៃ ដែលដឹកនាំដោយ ឯកឧត្តម **មុនស៊ីត ផែសានថាណាវ៉ាត់** អភិបាលខេត្តចាន់បុរី ដើម្បីពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងខេត្តនៅជាប់ព្រំដែន នៃប្រទេសទាំង២ ខេត្តប៉ៃលិន និងខេត្តចាន់បុរី ឱ្យបានកាន់តែល្អប្រសើរឡើងថែមទៀត បន្ទាប់ពីជម្ងឺកូវីដ-១៩ មានភាពជាប្រក្រតីឡើងវិញ និងដើម្បីទប់ស្កាត់រាល់បទល្មើសផ្សេងៗ ជាពិសេសទប់ស្កាត់ការឆ្លងដែនខុសច្បាប់។

**•ខេត្តកំពង់ស្ពឺ៖** លោក **ឡុង បូណារ៉េត** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំក្រុមការងារទាំង ៦ ទទួលជួបពិភាក្សាការងារជាមួយអង្គការផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្តីពីការជំរុញឱ្យទទួលបានភាពយុត្តិធម៌ និងសេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធវីដេអូ។

**•ខេត្តកណ្តាល៖** លោកជំទាវ **ហ៊ិន កុសនី** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ និងក្រុមការងារចំនួន ០៣រូប ទទួលជួបពិភាក្សាការងារជាមួយអង្គការអង្គការសកម្មភាពដើម្បីកុមារ (APLE) ស្តីពី "ការលើកកម្ពស់ការយល់ដឹង និងកម្មវិធីបណ្តុះបណ្តាលដែលបន្សីជាមួយផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើដូរមនុស្សខេត្តកណ្តាល" នៅសាលបន្ទប់ តាមប្រព័ន្ធវីដេអូ។

## គ. ការខារសម្របសម្រួល

គ.ជ.ប.ជ/គ.រ.ប.ជ/គ.ខ.ប.ជ និងអង្គការដៃគូ បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗទៀត ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្អែកលើផែនការជាតិយុទ្ធសាស្ត្រជាតិទាំងបួន (ការបង្ការ ទប់ស្កាត់ ការការពារ និងជួយជនរងគ្រោះ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងអំពើជួញដូរមនុស្ស) សរុបចំនួន **៥២៨**លើក មានអ្នកចូលរួមសរុប **៦.០៥៤**នាក់ (ស្រី **២.២៨២**នាក់) ដូចមានក្នុងតារាងខាងក្រោម៖

| សកម្មភាពចូលរួមរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ១៤៨ | ១.៥២២ | ៤៧០ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៧ | ១១៦ | ៦៨ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០៩ | ៧៨ | ២៥ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៧៥ | ៤៣៧ | ២១២ |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០៦ | ៧៩ | ៣២ |
| អង្គការមូលនិធិអេ២១ | ១៤ | ៥២ | ៣៧ |
| **ថ្នាក់ក្រោមជាតិ** | | | |
| រាជធានីភ្នំពេញ | ០៧ | ៤៩ | ១៥ |
| ខេត្តបន្ទាយមានជ័យ | ២៣ | ១.៥០៥ | ៤៦៨ |
| ខេត្តព្រះវិហារ | ០៩ | ៣៩ | ១៨ |
| ខេត្តបាត់ដំបង | ២៣ | ៩២០ | ៣៩៥ |
| ខេត្តពោធិ៍សាត់ | ០៦ | ២៥ | ០៩ |
| ខេត្តសៀមរាប | ៣៧ | ១០៧ | ៤៩ |
| ខេត្តឧត្តរមានជ័យ | ០៥ | ២០ | ០៩ |
| ខេត្តប៉ៃលិន | ១៣ | ១៩៨ | ៩៨ |
| ខេត្តកោះកុង | ០៦ | ៣២ | ១៣ |
| ខេត្តក្រចេះ | ០៨ | ១៧២ | ៤៩ |
| ខេត្តស្ទឹងត្រែង | ០៥ | ៣៩ | ២២ |
| ខេត្តរតនគិរី | ០៨ | ៣៦ | ១៥ |
| ខេត្តកំពង់ចាម | ១១ | ៥៥ | ១៨ |
| ខេត្តត្បូងឃ្មុំ | ១០ | ៦៧ | ៣៦ |
| ខេត្តមណ្ឌលគិរី | ០៤ | ២៥ | ០៩ |
| ខេត្តស្វាយរៀង | ០៨ | ៦៥ | ២៤ |
| ខេត្តកណ្តាល | ០៨ | ៤៣ | ១៩ |
| ខេត្តព្រៃវែង | ១៨ | ១៣៥ | ៦៧ |
| ខេត្តព្រះសីហនុ | ០៦ | ៣៩ | ១៣ |
| ខេត្តកំពត | ៧ | ២៦ | ១២ |

| | | | |
|---|---|---|---|
| ខេត្តកែប | ០៦ | ២៣ | ១២ |
| ខេត្តតាកែវ | ០៧ | ២៥ | ០៨ |
| ខេត្តកំពង់ឆ្នាំង | ៩ | ៤៧ | ១៩ |
| ខេត្តកំពង់ស្ពឺ | ០៦ | ២៣ | ០៩ |
| ខេត្តកំពង់ធំ | ០៩ | ៦៥ | ៣២ |
| **សរុប** | **៥២៨នាក់** | **៦.០៥៤នាក់** | **២.២៨២នាក់** |

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក. ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់ គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែកសម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ថ្វីត្បិតតែមានយន្តការក្នុងកិច្ចសហប្រតិបត្តិការគ្នា តែកិច្ច សហការមួយចំនួននៅមិនទាន់បានល្អនៅឡើយ។
- មន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមួយចំនួនមានការផ្លាស់ប្តូរ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំង និងរំលេចឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋាន គតិយុត្តនានាដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅអនុវត្តបន្តឆមាសទី២ ឆ្នាំ២០២៣

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

### ក. ការរៀបចំច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

១.បន្តរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលជាតម្រូវការចាំបាច់សម្រាប់បម្រើដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

២.ធ្វើបច្ចុប្បន្នភាពសៀវភៅ គោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

៣.គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ដើម្បីបន្តពិគ្រោះយោបល់ និងពិនិត្យឡើងវិញខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីអំពើពពោះជំនួស។

៤.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសកិច្ចសហការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ។

៥.បន្តជំរុញការអនុវត្តអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេស និងដៃគូពាក់ព័ន្ធដែលបានចុះហត្ថលេខារួចហើយ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល។

៦.បានចុះហត្ថលេខាលើស្តង់ដារនៃនីតិវិធីប្រតិបត្តិ(SOP) ស្តីពីកិច្ចសហការក្នុងការអនុវត្តច្បាប់ ដើម្បីប្រឆាំងការជួញដូរមនុស្ស និងត្រៀមរៀបចំផែនសកម្មភាពនៃ SOP រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស នៃព្រះរាជាណាចក្រថៃ។

៧.ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ របស់ក្រសួងសុខាភិបាល។

៨.រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីកសាងបទដ្ឋានគតិយុត្តនានា សម្រាប់ការពារសិទ្ធិ សុវត្ថិភាព ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទសមុទ្រ។

៩.ត្រៀមកិច្ចប្រជុំបួនប្រទេស កម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ក្នុងការពង្រឹងកិច្ចសហការ ការពារ និងបង្ការទប់ស្កាត់ ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសស្ត្រី និងកុមារ ក៏ដូចជាទារក។

១០.ត្រៀមបន្តចុះហត្ថលេខាអនុស្សរណៈ/កិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធ។

១១.បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីពង្រឹងការអនុវត្តវិធានការច្បាប់ វិធានការបង្ការទប់ស្កាត់ វិធានការសង្គ្រោះ និងការពារជនរងគ្រោះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១២.បន្តពង្រឹងយន្តការដឹកនាំបញ្ជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពទាំងលើការងារផ្សព្វផ្សាយអប់រំ និងការចាត់តាំងអនុវត្តច្បាប់ ព្រមទាំងជំរុញការតាមដានត្រួតពិនិត្យ និងកែលម្អជាប្រចាំចំពោះកិច្ចប្រតិបត្តិការរបស់មន្ត្រីអនុវត្តច្បាប់ សំដៅជំរុញឱ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាន់តែទទួលបានប្រសិទ្ធផលខ្ពស់។

## ខ. ការងារបង្ការ ទប់ស្កាត់

១.បន្តសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំយុទ្ធនាការ «គាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម»។

២.សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំសិក្ខាសាលាច្រកចេញចូលតែមួយ ស្តីពី «សេវាកម្មកុមារ»។

៣.ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ បន្តបើកវគ្គបណ្តុះបណ្តាលសៀវភៅសិក្សាអប់រំស្តីពី «ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន» ដល់គ្រូឧទ្ទេសក៏ថ្នាក់ជាតិ គ្រូឧទ្ទេសក៏គរុកោសល្យភូមិភាគ និងគ្រូបង្គោល តាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ នៅទូទាំងប្រទេស និងតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតខាងលើ។

៤.ក្រសួងទេសចរណ៍ បន្តការរៀបចំសិក្ខាសាលា ស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេចរណ៍ដល់ម្ចាស់មូលដ្ឋាន អាជីវកម្មសេវាកម្មទេសចរណ៍តាមបណ្តារាជធានី-ខេត្ត។

៥.សហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា(TRC) ធ្វើការផ្សព្វផ្សាយសារអប់រំ ដល់ប្រជាពលរដ្ឋ តាមរយៈទូរស័ព្ទចល័ត នៅថ្ងៃទិវាជាតិពាក់ព័ន្ធ។
៦.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដើម្បីជំរុញ និងពង្រីកការផ្សព្វផ្សាយអំពីឱកាសការងារឱ្យកាន់តែទូលំទូលាយនៅតាមសហគមន៍ ជាពិសេសសហគមន៍ ដែលងាយរងគ្រោះ រួមទាំងពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់។
៧.សហការជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតនីតិវិធីងាយស្រួលក្នុងការផ្សារភ្ជាប់ទំនាក់ទំនង និងការទទួលបានការប្រឹក្សាយោបល់ពីទីភ្នាក់ងារជាតិមុខរបរ និងការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីជម្រើសការងារ ឬមុខរបរ និងការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសផ្សេងៗសម្រាប់ក្រុមជនងាយរងគ្រោះ ជាពិសេសពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់ពីបរទេស។
៨.បន្តជំរុញការគ្រប់គ្រង និងធ្វើអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីធានាការអនុវត្តគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារ ក្នុងការការពារសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់ពលករក្នុងការធ្វើទេសន្តរប្រវេសន៍ការងារ។
៩.បន្តរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ និងវេទិកាជាតិអន្តរសាសនានៅកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
១០.បន្តសហការជាមួយអង្គការសហប្រជាជាតិ (IOM, WHO, UNFPA, UNICEF) និងដៃគូផ្សេងៗទៀត ដើម្បីរៀបចំកម្មវិធី ឆ្លើយតបទៅនឹងផលប៉ះពាល់លើសុខភាព និងជីវភាពពលករទេសន្តរប្រវេសន៍ និងគ្រួសារ ក្នុងស្ថានភាពនៃការរាតត្បាតដោយជំងឺកូវីដ-១៩ និងគ្រោះមហន្តរាយផ្សេងៗទៀត។
១១.បន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ការផ្សព្វផ្សាយអំពីការបង្ការ ទប់ស្កាត់ ការឆ្លង និងចម្លងជំងឺកូវីដ-១៩ និងផលប៉ះពាល់ ព្រមទាំងចុះតាមដានការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ។
១២.បន្តលើកកម្ពស់ការងារផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងពង្រីកការអប់រំតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយ អំពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងនិងក្រៅសាលារៀន និងជនងាយរងគ្រោះដទៃទៀត។
១៣.បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ដើម្បីកំណត់រកអំពើកេងប្រវ័ញ្ចផ្សេងៗ និងមានវិធានការក្នុងប្រភេទការងារដែលមានភាពរងគ្រោះខ្ពស់ ដូចជានៅតាមទីភ្នាក់ងារជ្រើសរើសពលករឯកជន រោងចក្រ សហគ្រាស សហគ្រាសឡឥដ្ឋ កសិដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ កន្លែងសេវាកម្សាន្តជាដើម។
១៤.លើកកម្ពស់ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងការអនុវត្តក្រមសីលធម៌ របស់ទីភ្នាក់ងារ និងកាត់បន្ថយការយកថ្លៃឈ្នួលពីពលករ ក្នុងនីតិវិធីនៃការជ្រើសរើសពលករទេសន្តរប្រវេសន៍។
១៥.បន្ត និងជំរុញរៀបចំផែនការអនុវត្តគោលបំណងអាទិភាព GCM និងអនុសញ្ញាអាស៊ាន។

## គ. ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ

១.បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
២.បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោស បទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្នុង និងក្រៅប្រទេស ជាពិសេសបទល្មើសថ្មី ដែលបង្កដោយជនបរទេស។

៣.បន្តពង្រឹងកិច្ចសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត ប្រមូល ភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសជួញដូរមនុស្ស។

៤.បន្តពង្រឹងកិច្ចសហការជាមួយសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការងារអនុវត្តច្បាប់ និងយុត្តិធម៌ ព្រហ្មទណ្ឌ ក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន។

៥.ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

## ឃ. ការងារការពារជនរងគ្រោះ

១.ជំរុញប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករ ជាពិសេស ពលករដែលមិនមានឯកសារស្របច្បាប់ នៅក្នុងវដ្ត នៃទេសន្តរប្រវេសន៍ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយ និងវិធានការសម្រាប់ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ និងការផ្តល់សេវាឱ្យបានសមស្រប ។

២.បន្តពង្រឹងយន្តការសម្រាប់ការទទួលពលករ ការគ្រប់គ្រង និងដំណើរការមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង ដោយមានកិច្ចសហការពីបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ ក្នុងការផ្តល់សេវា។

៣.រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ ក្នុងទេសន្តរប្រវេសន៍ ពីអំពើជួញដូរមនុស្ស និងការរំលោភបំពាន។

៤.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តរៀបចំវគ្គបណ្តុះបណ្តាលៈ

- គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- គោលការណ៍ណែនាំ ស្តីពី «បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ដល់មន្ត្រីជួរមុខ។

៥.ធ្វើបច្ចុប្បន្នភាពលើនីតិវិធីប្រតិបត្តិបទដ្ឋាន(SOPs) ស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

៦. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បន្តកិច្ចសហប្រតិបត្តិការជាមួយៈ

- ក្រសួងសុខាភិបាល ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យទទួលបានសេវាពិនិត្យសុខភាព និងការព្យាបាលសង្គ្រោះបន្ទាន់ដោយឥតគិតថ្លៃ នៅតាមមជ្ឈមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ។
- ស្ថានទូត និងកុងស៊ុល នៅក្រៅប្រទេស(តាមរយៈក្រសួងការបរទេស) ដើម្បីជួយដល់ជនរងគ្រោះ និង សម្រួលដល់ដំណើរការមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាឱ្យបានឆាប់រហ័ស និងមានសុវត្ថិភាព។
- ក្រសួងស្ថាប័ន និងអង្គការដៃគូ ដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៧.បន្តចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៨.ពិនិត្យលទ្ធភាព ដើម្បីបង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះជារបស់រដ្ឋ។

៩.គាំទ្រក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធនៅក្នុងស្ថាន តំណាងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសគោលដៅ អំពីគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

១០.រៀបចំឧបករណ៍វាយតម្លៃអំពីភាពប្រឈមនៃមេរៀន ស្តីពី«ការអនុវត្តនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ក្នុងខេត្តដែលបានបណ្តុះបណ្តាលរួចហើយ។

១១.រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតាមមណ្ឌល និងនៅតាមសហគមន៍។

## ខ. ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ

១.ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន ការងាររបាយការណ៍ ការកសាងផែនការ និងការងារត្រួតពិនិត្យ វាយតម្លៃ។

២.បន្តធ្វើការប៉ាន់ប្រមាណ និងវាយតម្លៃពាក់កណ្តាលអាណត្តិ ទៅលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំយន្តការប្រមូលទិន្នន័យ ថ្នាក់ជាតិ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសទិន្នន័យនៃការអនុវត្តច្បាប់ ការផ្តន្ទាទោស និងការងារការពារជនរងគ្រោះឱ្យមានសង្គតិភាព។

៤.គាំទ្រពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រង គ្រប់ផ្នែក ដល់មន្ត្រីជំនាញក្នុងក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត ដើម្បីពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥.បន្តធ្វើសេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការរាជធានី ខេត្ត។

៦.រៀបចំប្រព័ន្ធប្រមូល ចងក្រង និងចែកចាយទិន្នន័យ តាមផ្នែកពាក់ព័ន្ធសំខាន់ៗ។

ថ្ងៃអង្គារ ៣ កើត ខែអាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៧ ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**
- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"